ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណេះមិត្តអាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពុទ្ធិនិងពុទ្ធិកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សំការៈ

ឡសូនាវីត្តី

ត្រូបទ្រៀន

សាលារៀនបណ្ណេតទឹក

ខែ តុលា-វិច្ឆិកា-ធ្នូ ឆ្នាំ ២០០៧

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨៩ មហាវិថីព្រះនរោត្តម (ភ្នំពេញ)

ទូរស័ព្ទ : ០២៣ ២១៦ ១៨៤-០១១ ៨៨៣ ៩៨៨

មាតិកា

ស.រ	ចំណងជើងអត្ថបទ	ទំព័រ
១	វិចារណកថា	១
	ចប្បធម៌ទូទៅ	
២	សេដ្ឋកិច្ចអប់រំនៅកម្ពុជា	២
៣	ទិសដៅ និងវត្ថុបំណង	៥
៤	ដំបងក្រញូង និងប្រវត្តិខេត្តបាត់ដំបង	៥
	ចិត្តវិទ្យា-អប់រំ	
៥	ការដកពិសោធន៍របស់កុមារអាយុ ១២ខែ ដល់ ១៥ខែ	១២
៦	គំរូថ្មីនៃការអភិវឌ្ឍជំនាញ	១៥
៧	ទំនាក់ទំនងរវាងមជ្ឈដ្ឋាន គេហដ្ឋាន និងសាលារៀន (ត)	១៧
	វិទ្យាសាស្ត្រ និងពត៌មានវិទ្យា	
៨	ការជួយព្យាបាលនៃជំងឺបេះដូង	១៥
៩	ដេស៊ីបែល	២០
	ការអប់រំ និងគរុកោសល្យ	
១០	ល្បិចបង្រៀន : ការស្រាវជ្រាវរបស់សិស្ស (ត)	២១
១១	កុមារត្រូវការអ្វីខ្លះដើម្បីចាប់ផ្តើមរៀនអាន?	២៤
១២	គណិតវិទ្យា : វិធីបូក	២៧
១៣	សិក្សាសង្គម : ភូមិវិទ្យា "អាកាសធាតុប្រទេសកម្ពុជា"	២៥
១៤	គំនូរ : វិធីបង្រៀនគំនូរ (ត)	៣០
	នាទីកំណាព្យ និង កំសាន្ត	
១៥	ម៉ែ	៣៣
១៦	ឧត្តមគតិ ស.ប.ស.ខ.	៣៥
១៧	ល្បែងកំសាន្ត	៣៦
១៨	រឿងហង្ស និងក្អែក និងរឿងក្អែក និងទទា	៣៧
	វេទិកាស្វែរិន	
១៩	ប្រវត្តិបទនគររាជ ភ្លេងជាតិខ្មែរ	៣៨
២០	វេទិកាស្ត្រី : សិទ្ធិស្ត្រី គឺជាសិទ្ធិមនុស្ស	៤០
	ពត៌មាន	
២១	តើលោកគ្រូ អ្នកគ្រូ ដឹងទេថា...	៤២
២២	តារាងស្ថិតិសាលារៀន ថ្នាក់រៀន សិស្ស និងបុគ្គលិក...	៤៤
២៣	ស្ថិតិសពខែកក្កដា-សីហា-កញ្ញា ឆ្នាំ២០០៧	៤៧

គណៈកម្មការរៀបរៀង និងនិពន្ធ

- លោក កែវ យ៉ារ
- លោកស្រី ហូរ សីរី
- លោកស្រី ប៉ែន ណារុល
- លោក ថោង ឃូរ៉ាន់
- លោក ស្រី គុយ ផល្លា
- លោកស្រី ប្រាក់ សូលីដា
- លោក ជន ឈានលី
- លោក កៅ ជឿន
- លោក ស្វាយ ទិត្យ
- លោក ជុំ ហ៊ីន
- លោក ប៉ែន សារុន
- សមាជិក-សមាជិកាស.ប.ស.ខ

គណៈកម្មការត្រួតពិនិត្យ

- លោក យស់ អ៉ាង
- លោក សូង សារុណ
- លោក ស៊ុង រ៉ាន់ថន
- លោកបណ្ឌិត អ៊ីម កុច
- លោក ស៊ុន ស៊ីម
- លោក អ៊ុន ថេរ
- លោកស្រី ទន់ សាអ៊ីម

ទិចិត្រករ

លោក ចាន់ ត្រា

ការីកុំព្យូទំរ

កញ្ញា ម៉ៃ សូនី

ក្រុមខាងក្រៅ

- ពីមុខ: សាលារៀនបណ្ណែតទឹក
- ពីក្រោយ: មន្ត្រីចតុស្តម្ភ

ទូរស័ព្ទផ្ទះក្រុមប្រៀន

ភ្នំពេញ : ០១២ ៨៩៧ ១៧៧, កំពត : ០១២ ៨៥៦ ៧២២, ក្រុងព្រះសីហនុ : ០១២ ៦៥៩ ៥៦០

សៀមរាប : ០១២ ៦៧៥ ៦៤០ តាកែវ : ០១២ ១ ៧០៣ ០២៧ កំពង់ចាម : ០១១ ៧៤២ ២២៤

វិចារណកថា

ប្រជាជនខ្មែរទូទៅបានចាត់ទុកដោយមានទម្ងន់ផ្នែកសីលធម៌ថា "លោកគ្រូ អ្នកគ្រូ ជាមាតាបិតាទី២ នៃបុត្រធីតារបស់ខ្លួន"។ ការវាយតម្លៃនេះពិតជាត្រឹមត្រូវ ព្រោះពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំ គ្រូបង្រៀនក្នុងភារកិច្ចជាអ្នកអប់រំបណ្ដុះបណ្ដាល ជាគរុកោសល្យវិទូបានខិតខំដោយអំណត់ព្យាយាម និងសេចក្ដីស្រឡាញ់ ដើម្បីផ្ទេរចំណេះដឹងដែលជាតម្លៃនៃវិទ្យាសាស្ត្រ បច្ចេកទេស នៃអាកប្បកិរិយា គំរូល្អនៃសីលធម៌ គុណធម៌ ពោលគឺ ៖

- រៀនដើម្បីចេះ មានន័យថា ជាការទទួលបានឧបករណ៍នៃការយល់ដឹង
- រៀនដើម្បីធ្វើ មានន័យថា ជារបៀបធ្វើដោយច្នៃប្រឌិតជុំវិញបរិស្ថានរបស់ខ្លួនឯង
- រៀនដើម្បីមានសីលធម៌ល្អ មានន័យថា ជាលក្ខណៈនៃការលូតលាស់ផ្ទាល់ និងការរីកចម្រើនផ្នែកបុគ្គលិកលក្ខណៈ ដែលដំណាក់កាលនេះជាការស្គាល់ខ្លួនឯង និងបើកចំហទំនាក់ទំនងជាមួយអ្នកដទៃ
- រៀនដើម្បីរស់នៅជាមួយគ្នា មានន័យថា ជារបៀបចូលរួម និងសហការជាមួយមនុស្សដទៃទៀត

ចំពោះកុមារា កុមារី សិស្ស និស្សិត នៅគ្រប់ទីកន្លែងដែលពួកគេរស់នៅក្នុងកាលៈទេសៈណាក៏ដោយ គឺប្រែក្លាយពួកគេជាពលរដ្ឋល្អ មានសមត្ថភាពរួមចំណែកក្នុងការកសាង និងការការពារប្រទេសជាតិ ។

បន្ថែមទៀត គ្រូបង្រៀនក្នុងភារកិច្ចជាអ្នកកសាងអនាគតរបស់កុមារា កុមារី សិស្ស និស្សិត ហើយទទួលបានជោគជ័យក្នុងការបង្កើតបរិយាកាស គោរពបុគ្គលខ្លួនឯង អត់អោនគ្នា ផ្ដល់លទ្ធភាពឱ្យពួកគេមានទំនាក់ទំនងកាន់តែប្រសើរឡើង ដោះស្រាយបញ្ហាផ្សេងៗតាមរបៀបរស់នៅមួយសម្រាប់ទាំងអស់គ្នា មានផ្នត់គំនិតស្រឡាញ់យុត្តិធម៌... ដែលទាំងអស់នេះជាលក្ខណៈចាំបាច់សម្រាប់ភាពសុខដុមរមនារបស់សង្គម ដរាបនោះគោលដៅចុងក្រោយនៃការសិក្សាអប់រំនឹងក្លាយជាការពិត ។

ដូចនេះ បើគ្មានវិភាគទានពីគ្រូបង្រៀនក្នុងការកសាងមនុស្សទេ នោះការប្រឹងប្រែងដទៃទៀតនឹងពុំអាចសម្រេចបានឡើយ ។

អង្គការអន្តរជាតិនៃការងារ (OIT) និងអង្គការយូណេស្កូ (UNESCO) បានទទួលស្គាល់ថា ការប្រឆាំងនឹងភាពក្រីក្រជាគោលដៅសហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ បាននិងកំពុងជាកង្វល់របស់ពិភពលោក ។ ក្នុងទស្សនៈនេះ គេត្រូវផ្ដល់អាទិភាពទៅលើការសិក្សាអប់រំ ហើយដាក់គ្រូបង្រៀនជាស្នូលនៃការអភិវឌ្ឍសង្គម។ គ្រប់យុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រ ត្រូវតែគិតដល់យុទ្ធសាស្ត្រដោយឡែកសម្រាប់ផ្ដល់ឱកាសដល់អ្នកមានការលំបាក ដូចជាកុមារី និងស្ត្រីនៅជនបទ ក្មេងកំព្រាដែលឪពុកម្ដាយស្លាប់ដោយជំងឺអេដស៍ ដើម្បីឱ្យពួកគេអាចទទួលបានសិទ្ធិការសិក្សាអប់រំ ។

គឺក្នុងស្មារតីទាំងអស់នេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យប្រកាសបង្កើតទិវាគ្រូបង្រៀន ដោយកំណត់យកថ្ងៃទី៥ តុលា រៀងរាល់ឆ្នាំ ជាទិវាប្រារព្ធពិធីដ៏ឧត្ដុង្គឧត្ដមនេះស្របតាមទិវាសកលនៃគ្រូបង្រៀនក្នុងន័យឱ្យសិស្សានុសិស្សខិតខំរៀនសូត្រ ឱ្យមាតាបិតាយកចិត្តទុកដាក់ដល់កូនចៅរបស់ខ្លួន ឱ្យសង្គមទាំងមូលផ្ដល់គុណតម្លៃដល់គ្រូ បង្រៀន ។

សូមទិវាគ្រូបង្រៀន ៥ តុលា ក្លាយជាទិវាដែលសង្គមជាតិទាំងមូលនឹកឃើញពីអនុស្សាវរីយ៍ពោរពេញដោយការគោរព និងការស្រឡាញ់រវាងគ្រូ និងសិស្ស ៕

គណៈកម្មាធិការកណ្ដាល

សេដ្ឋកិច្ចអប់រំនៅកម្ពុជា

សេចក្តីផ្តើម

សូក្រាតធ្លាប់លាន់ថា : មានរឿងល្អតែមួយប៉ុណ្ណោះ គឺចំណេះវិជ្ជា ហើយនិងមានរឿងអាក្រក់តែមួយប៉ុណ្ណោះគឺ ភាពអវិជ្ជា (There is only one good, knowledge, and one evil, ignorance) ។

នៅពេលដែលសហភាពសូវៀតបានបាញ់ប្រហារផ្កាយរណបអវកាសស្ពុតនិកជាលើកដំបូងនៅឆ្នាំ១៩៥៧ សហរដ្ឋអាមេរិកបានភ្ញាក់ផ្អើលស្រឡាំងកាំងជាខ្លាំង ដោយបានលើកសំណួមពរភ្លាមៗឱ្យគេពិនិត្យមើលដោយយកចិត្ត ទុកដាក់ទៅលើការបង្រៀនវិទ្យាសាស្ត្រនៅតាមសាលារៀន។ ក្រោយមកគេបានរកឃើញថា វាពិតជាមានចំណុចខ្វះខាតមែន បន្ទាប់មកគេបានទាមទារឱ្យការផ្លាស់ប្តូរនូវកង្វះខាតនេះជាបន្ទាន់ ។ គេបានឱ្យអ្នកវិទ្យាសាស្ត្រចូលរួមក្នុងការផ្តល់យោបល់ ថាតើត្រូវបង្រៀនមេរៀនយ៉ាងដូចម្តេច ទើបទទួលបានផលល្អ ។

នៅទសវត្សរ៍ឆ្នាំ៨០ ដោយសារតែមានឥទ្ធិពលខាងសេដ្ឋកិច្ច នៅសហរដ្ឋអាមេរិកដែលនេះគេបានចាប់ផ្តើម រាយតម្លៃឡើងវិញនូវប្រព័ន្ធអប់រំតាមកម្រិតសាលា ដើម្បីអាចឃើញពីរបៀបបណ្តុះបណ្តាលធនធានមនុស្សក្នុងការចូលរួមដល់ការអភិវឌ្ឍសង្គម។ គណៈកម្មាធិការផ្សេងៗត្រូវបានគេបង្កើតឡើងដើម្បីធ្វើសកម្មភាពនេះ ។ ត្រីមាសវិភាគបានប្រកាសនៅឆ្នាំ១៩៨៥ ថា ជាក្តីកង្វល់ពីគុណភាពនៃការបង្រៀន និងបង្កើតក្រុមការងារខែដល់ក្រុមគ្រូបង្រៀន ។ បន្ទាប់មក គេបានរកឃើញ ថា នៅទសវត្សរ៍ឆ្នាំ៩០ គុណភាពនៃការសិក្សាបានកើនឡើង ។ ដូច្នេះយើងសង្កេតឃើញថា ដើរសហរដ្ឋអាមេរិកបាន ធ្វើអ្វីខ្លះដើម្បីគុណភាពអប់រំ ។

ដើម្បីយល់ដឹងអំពីសេដ្ឋកិច្ចអប់រំគេត្រូវស្វែងយល់អំពីនិយមន័យ : សេដ្ឋកិច្ចវិទ្យា ការអប់រំ និងសេដ្ឋកិច្ច អប់រំ ។

តើដូចម្តេចដែលហៅថា សេដ្ឋកិច្ចអប់រំ ហើយមុខវិជ្ជានេះមានគោលការណ៍សំខាន់ៗអ្វីខ្លះ?

តាមរយៈការសិក្សាមុខវិជ្ជាសេដ្ឋកិច្ចអប់រំ យើងនឹងដឹងអំពីបញ្ហាសំខាន់ៗផ្សេងៗ នឹងមូលដ្ឋាននៃមុខវិជ្ជា នេះ ។ តាមរយៈមុខវិជ្ជានេះ គេនឹងយល់ដឹងអំពីទំនាក់ទំនងរវាងការអប់រំ និងសង្គម, ការអប់រំ និងសេដ្ឋកិច្ច ពោលគឺ

តួនាទីរបស់ការអប់រំនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ។ តើសេដ្ឋកិច្ចអប់រំមានទំនាក់ទំនងនឹងការអប់រំយ៉ាងដូចម្ដេច?

តាំងពីទសវត្សឆ្នាំ៦០ ទ្រឹស្ដីសេដ្ឋកិច្ចត្រូវបានគេយកមកប្រើប្រាស់នៅក្នុងបញ្ហាអប់រំ ។ ការសិក្សាមុខវិជ្ជាសេដ្ឋកិច្ចអប់រំនឹងនាំណែនាំឱ្យស្គាល់ពីទ្រឹស្ដីខ្លះៗដូចជា [illegible] ក្នុងវិស័យអប់រំ [illegible] ក្នុងការវិនិយោគលើវិស័យអប់រំ ការអប់រំ និងការរីកចម្រើននៃសេដ្ឋកិច្ច ផែនការអប់រំ ចំណាយលើការអប់រំ [illegible] និងពលកម្ម ការបញ្ជាក់ពីអត្តសញ្ញាណ និងការវាស់វែងពីតម្លៃសេដ្ឋកិច្ចអប់រំ [illegible] ។ល។

ការសិក្សាទ្រឹស្ដីសេដ្ឋកិច្ចអប់រំនេះ តាមរយៈការវិភាគ និងការពិនិត្យមើលទៅលើអត្រាផលប្រយោជន៍ផ្ដល់ឱ្យបុគ្គល និងសង្គម លើការវិនិយោគក្នុងការអប់រំនេះ អាចជួយឱ្យយើងពង្រីកនូវគំនិតឱ្យកាន់តែទូលំទូលាយ [illegible] វិភាគបញ្ហាអប់រំតាមបែបសេដ្ឋកិច្ច ហើយក៏អាចជួយផងដែរក្នុងការរៀបចំគម្រោងផែនការអប់រំ និងគោលនយោបាយអប់រំ ។ ការសិក្សានេះនឹងមានប្រយោជន៍ ជាពិសេសចំពោះអ្នកគ្រប់គ្រងអប់រំ និងអ្នកអប់រំ [illegible] ។

១. និយមន័យ

ក. សេដ្ឋកិច្ចវិទ្យា

នៅឆ្នាំ១៩៦១ សាស្ត្រាចារ្យ Samuelson បានបញ្ជាក់ថា ពាក្យសេដ្ឋកិច្ចវិទ្យាពុំមែនមានតែនិយមន័យមួយប៉ុណ្ណោះទេ ។ ទោះជាយ៉ាងនេះក៏ដោយ [illegible] ៖

"សេដ្ឋកិច្ចវិទ្យា គឺជាការសិក្សាអំពីរបៀបដែលមនុស្ស និងសង្គមជ្រើសរើសដោយប្រើ ឬមិនប្រើលុយកាក់ ដើម្បីប្រើប្រាស់ធនធានផលិតផលកម្រទៅផលិតទំនិញផ្សេងៗគ្រប់ពេលវេលា ហើយចែកចាយទំនិញទាំងនោះសម្រាប់យកទៅប្រើប្រាស់ក្នុងចំណោមមនុស្ស និងក្រុមមនុស្សផ្សេងគ្នាក្នុងសង្គម នៅពេលបច្ចុប្បន្ន និងទៅអនាគត" ។

តាមន័យនេះ សេដ្ឋកិច្ចវិទ្យាគឺជាការសិក្សាអំពីផលិតកម្ម និងការចែកចាយ [illegible] មិនថាតែជាទំនិញ ឬសេវាកម្មដែលមានអ្នកប្រើប្រាស់ឡើយ ។

ពាក្យគន្លឹះនៅទីនេះ គឺ៖ [illegible]

[illegible] សេដ្ឋកិច្ចវិទ្យា [illegible] (និងសេវាកម្មដែលមានតម្លៃ [illegible] និងទំនិញសេវាកម្មផ្សេងទៀតដែលមនុស្សត្រូវការ ។ សេដ្ឋកិច្ចវិទ្យា មានការទាក់ទងទៅនឹងការចែកចាយ [illegible] សេដ្ឋកិច្ចទូ [illegible] មានភារកិច្ចទទួលខុសត្រូវលើដំណើរការនៃប្រព័ន្ធសេដ្ឋកិច្ចទាំងផ្នែកទូលាយ ដូចជា សេដ្ឋកិច្ចសហរដ្ឋអាមេរិកទាំងមូល ទាំងប្រព័ន្ធសេដ្ឋកិច្ចចង្អៀត ដូចជាក្រុមហ៊ុនជាក់លាក់មួយ ។

ខ. ការអប់រំ

យោងទៅលើវចនានុក្រម New World របស់ Webster (1962) បានឱ្យនិយមន័យថា ÷

"ការអប់រំ ជាលំនាំនៃការបណ្ដុះបណ្ដាល និងការអភិវឌ្ឍចំណេះដឹង បំណិន គំនិត អត្តចរិត ។ល។ ជាពិសេស

តាមរយៈការសិក្សាក្នុងប្រព័ន្ធ។

សកម្មភាពអប់រំទាក់ទងទៅនឹងការផលិត និងការចែកចាយចំណេះដឹង មិនចាំបាច់ឡើយសកម្មភាពទាំងនោះត្រូវបានគេអនុវត្តនៅក្នុងគ្រឹះស្ថានសិក្សាជាប្រចាំ ឬកន្លែងជាប់លាប់ឡើយ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សកម្មភាពជាច្រើនបានកើតឡើងនៅតាមគ្រឹះស្ថានសិក្សាដូចជា សាលាបឋមសិក្សា សាលាមធ្យមសិក្សា និងស្ថាប័នឧត្តមសិក្សារដ្ឋ ឬឯកជន ។ ការបញ្ជាក់អំពីសេដ្ឋកិច្ចផ្តោតសំខាន់លើការអប់រំក្នុងប្រព័ន្ធ។

ទោះបីយ៉ាងនេះក៏ដោយ គេទទួលស្គាល់ថា សកម្មភាពអប់រំប្រកបដោយចីរភាពត្រូវបានអនុវត្តឡើងនៅតាមគ្រឹះស្ថាននានា រួមមានសាលាសមាគម ព្រះវិហារ មជ្ឈមណ្ឌលកំសាន្ត និងក្រុមហ៊ុនផ្សេងៗ។

គ.សេដ្ឋកិច្ចអប់រំ

ដោយផ្អែកលើនិយមន័យសេដ្ឋកិច្ចវិទ្យា និងនិយមន័យអប់រំនោះ និយមន័យសេដ្ឋកិច្ចអប់រំត្រូវបានគេបង្កើតឡើង ។

"សេដ្ឋកិច្ចអប់រំ គឺជាការសិក្សាពីរបៀបដែលមនុស្ស និងសង្គមជ្រើសរើសដោយប្រើ ឬមិនប្រើលុយកាក់សម្រាប់ប្រើប្រាស់ធនធានដែលកម្រ ដើម្បីផលិតការបណ្តុះបណ្តាលផ្សេងៗ រួមមានការអភិវឌ្ឍចំណេះដឹង បំណិន ចិត្តគំនិត អត្តចរិត ។ល។ ជាពិសេសតាមរយៈការអប់រំក្នុងប្រព័ន្ធក្នុងពេលវេលា និងដើម្បីចែកចាយធនធានទាំងនោះក្នុងចំណោមមនុស្ស និងក្រុមមនុស្សនៅក្នុងសង្គម នាពេលបច្ចុប្បន្ន និងនៅអនាគត"។

ក្នុងន័យនេះ ការអប់រំជាប់ទាក់ទងទៅនឹង ៖

- ផលិតផលនៃការអប់រំដែលបានផលិត
- ការចែកចាយការអប់រំក្នុងចំណោមក្រុម ឬបុគ្គលផ្សេងៗក្នុងប្រព័ន្ធ
- បញ្ហាផ្សេងៗដែលគេចាត់ទុកថា សង្គមគួរតែចំណាយពេលច្រើនលើការគ្រប់គ្រងការអប់រំ ហើយប្រភេទបែបណាមួយនៃការអប់រំគួរតែត្រូវបានគេជ្រើសរើសឡើង ។

លោក Beeby (១៩៦៦) បានលើកជាការអះអាងថា សេដ្ឋកិច្ចវិទូ គួរតែទាក់ទងទៅនឹងផលិតភាពនៃការអប់រំដែលគេចាត់ទុកថា ស្ថិតនៅក្រោមបន្ទប់រៀន និងនៅក្នុងទីផ្សារដែលគុណភាពការអប់រំត្រូវបានវាស់តាមរយៈសកម្ម-ភាពផលិត ។ ប៉ុន្តែការទទួលបាននៃការសិក្សាសេដ្ឋកិច្ចអប់រំគួរតែ ... និងរឿងរ៉ាវផ្សេងៗ ... Beeby ... សេដ្ឋកិច្ចអប់រំ ... លោក ... ប ...

ꩰ📖ꩰ

ទិសដៅ ចំនុចគន្លឹះ

អ្វីដែលហៅថា ទិសដៅ? តើទិសដៅខុសគ្នាដូចម្តេចពីចក្ខុវិស័យ? តើគេអាចកំណត់ទិសដៅដោយវិធីណា?

ចក្ខុវិស័យត្រូវបំបែកជាគោលដៅតូចៗដែលអាចធ្វើឱ្យសម្រេចបានហៅថា ទិសដៅ។ ដើម្បីធ្វើឱ្យសម្រេចនូវចក្ខុវិស័យរបស់ខ្លួន នាយកសាលានីមួយៗត្រូវទាមទារឱ្យកំណត់បាននូវទិសដៅរបស់សាលាខ្លួន។ ចក្ខុវិស័យត្រូវបានលើកឡើងជាទូទៅ និងពុំមានការកំណត់ពេលវេលាទេ។ ប៉ុន្តែចំពោះទិសដៅវិញនោះ វាត្រូវតែមានភាពច្បាស់លាស់ជាក់លាក់ និងមានពេលវេលាកំណត់មួយ។ សាស្ត្រាចារ្យសាស្ត្រាចារ្យ ហ៊ីន សែន បានលើកឡើងថា ផែនការត្រូវតែប្រកបដោយរចនាសម្ព័ន្ធល្អ ជាក់ស្តែង ច្បាស់លាស់ និងតម្លាភាពឡើងដោយភាពជាម្ចាស់ និងការទទួលខុសត្រូវ។ ជាទូទៅ SMART[1] ត្រូវបានណែនាំឱ្យអ្នកធ្វើផែនការទាំងឡាយប្រកាន់យកភាព ÷

- ជាក់លាក់ (Specific)
- អាចវាស់វែងបាន (Measurable)
- អាចធ្វើឱ្យសម្រេចបាន (Acthevable)
- ជាក់ស្តែង (Realistic)
- មានពេលកំណត់មួយ (Time based)

នាយកសាលាដែលប្រើនៅតាមសំណួមពាឱ្យមានតំរូវភាពមួយក្នុងការធ្វើផែនការ។ លើសពីនេះទៀត អ្នកធ្វើអធិការកិច្ចខ្លះបានទាមទារឱ្យនាយកសាលាប្រកាន់យកវិធីតំរូវមួយដែលត្រូវបានមកភាពល្អហើយ។ ប្រការនេះតានតឹងឱ្យនាយកសាលាមួយចំនួនមានការភ័យខ្លាចមិនហ៊ានតិះដៀលអ្នកទិសដៅផ្ទាល់ខ្លួន ហើយម្យ៉ាងទៀតអ្នកនូវទិសដៅដែលមានប្រទាក់ពីមួយទៅមួយ។ តាមពិតទៅ សាលារៀនមានលក្ខណៈពិសេសពីមួយទៅមួយ ហើយសាលារៀនមួយៗក៏គួរមានទិសដៅដោយខ្លួនឯងដែរ។

នាយកសាលាភាគច្រើនយល់ថានូវទិសដៅដែលល្អគឺជាការ។ គឺជាការប្តាក់ធ្ងន់ធ្ងរ ពីព្រោះជាទូទៅភាពឥតខ្ចោះរមែងមិនអាចធ្វើឱ្យសម្រេចបាន ហើយបរាជ័យក្នុងការអនុវត្ត និងនាំឱ្យអ្នកអនុវត្តមានអារម្មណ៍បាត់ទំនុកចិត្តផ្ទាល់ខ្លួន។ ប៉ុន្តែក៏ត្រូវចងចាំថា ទិសដៅដ៏ល្អបានណា ក៏មិនលើកកម្ពស់ការខំប្រឹងប្រែងដែរ។ ដូចគេ ទិសដៅគួរតែមានភាពជាក់ស្តែង និងមានការលំនាំតម្រង់ប្រាន់ក្នុងការលើកកម្ពស់ការខំប្រឹងប្រែង។

ដើម្បីកំណត់នូវទិសដៅដ៏ឱ្យមានភាពជាក់ស្តែង នាយកសាលាត្រូវវិភាគមកលើចក្ខុវិស័យ ហើយសាកល្បងបកស្រាយឱ្យទៅជាអ្វីដែលអាចប៉ះពាល់ដោយ។ ឧទាហរណ៍ ការធ្វើឱ្យសម្រេចនូវចក្ខុវិស័យ "ផ្តល់នូវការអប់រំដោយមិនលំអៀងសម្រាប់កុមារទាំងអស់គ្នា" អាចបកស្រាយបានទៅជា ៖ ១- ប្រមូលកុមារក្នុងវ័យសិក្សាឱ្យបានចូលសាលា ២- កសាងអគារ

(1) អក្សរកាត់នៃរចនាសម្ព័ន្ធទិសដៅ

សិក្សាឱ្យបានគ្រប់គ្រាន់សម្រាប់ពួកគេ និង ៣-ផ្តល់នូវសម្ភារៈរៀនឱ្យបានគ្រប់គ្រាន់ឱ្យពួកគេ ។ ក្នុងន័យនេះ ការធ្វើឱ្យសម្រេចនូវចក្ខុវិស័យដែលត្រូវបានកំណត់ខាងលើ គឺត្រូវធ្វើឱ្យប្រមូលកុមារទាំងអស់ក្នុងវ័យសិក្សាឱ្យបានចូលរៀនយកចិត្តទុកដាក់ថែរក្សា និងជួយទ្រទ្រង់ពួកគេទាំងអស់គ្នាឱ្យរៀនបានប្រកបដោយជោគជ័យ ។ ដូចនេះ ទិសដៅប្រចាំឆ្នាំអាចមានដូចខាងក្រោម :

១- ប្រមូលកុមារក្នុងវ័យសិក្សាទាំងអស់ឱ្យបានចូលរៀន

២- ធ្វើឱ្យបរិដ្ឋានសាលារៀនមានភាពកក់ក្តៅ និងទ្រទ្រង់ការរៀន

៣- ផ្តោតការយកចិត្តទុកដាក់លើការបង្រៀន និងរៀនភាសា កុមារម្នាក់ៗមានឱកាសរៀន និងអភិវឌ្ឍសមត្ថភាពរបស់គេ

៤- ផ្តល់ការជួយឧបត្ថម្ភដោយឡែកចំពោះសិស្សរៀនយឺត និងកុមារដែលមានការលំបាក

៥- លើកកម្ពស់ឱ្យបានខ្លាំងក្លានូវការចូលរួមរបស់សហគមន៍ និងមាតាបិតាសិស្សក្នុងសកម្មភាពរបស់សាលារៀន ។

២-វត្ថុបំណង

អ្វីដែលហៅថា វត្ថុបំណង? តើត្រូវកំណត់វត្ថុបំណងយ៉ាងដូចម្តេច?

ដើម្បីឈានធ្វើឱ្យសម្រេចនូវទិសដៅនោះ នាយកសាលាត្រូវកំណត់វត្ថុបំណង ។ ទិសដៅមួយៗអាចមានវត្ថុបំណងច្រើន ។ កន្លងមក មានវិធីពីរក្នុងការកំណត់វត្ថុបំណង ។ អ្នកខ្លះធ្លាប់ប្រើនូវគោលវិធីសមហេតុសមផល (Logical Framework Approaches-LFA) ក្នុងការធ្វើការវិភាគស្ថានភាព និងកំណត់នូវវត្ថុបំណង ។ គោលវិធីសមហេតុសមផល ត្រូវបានគេធ្លាប់ប្រើទូទៅដោយអ្នកធ្វើផែនការនានា ប៉ុន្តែវិធីនេះពិបាកយល់ និងពិបាកអនុវត្តខ្លាំងចំពោះនាយកសាលាជាច្រើន ។ អ្នកធ្វើផែនការខ្លះប្រើប្រាស់ការវិភាគតាមវិធី SWOT ។ SWOT ជាអក្សរកាត់នៃ Strengths (ចំណុចខ្លាំង) Weakness (ចំណុចខ្សោយ) Opportunities (ឱកាស) និង Threats (ឧបសគ្គ) ។

១- ចំណុចខ្លាំង គឺជាចំណុចល្អដែលមាននៅក្នុងស្ថាប័នមួយៗ ។ វាអាចជាគុណសម្បត្តិដែលស្ថាប័ននោះមាន ។

ឧទាហរណ៍ : ការចូលរួមយ៉ាងខ្លាំងក្លារបស់សហគមន៍អាចរាប់ថាជាចំណុចខ្លាំងមួយរបស់សាលារៀន ។

២- ចំណុចខ្សោយ : គឺជាវិស័យដែលទាមទារឱ្យមានការកែលម្អ ដូចជាអត្រាបោះបង់របស់សិស្សខ្ពស់ អត្រាត្រួតថ្នាក់ខ្ពស់ ជាដើម ។

៣- ឱកាស : ជាកត្តាដែលជួយឱ្យសាលារៀនអាចធ្វើឱ្យសម្រេចនូវទិសដៅរបស់ខ្លួន ។

៤- ឧបសគ្គ : គឺជាកត្តាដែលរារាំងមិនឱ្យសាលារៀនធ្វើឱ្យសម្រេចនូវទិសដៅរបស់ខ្លួន ។

ចំណុចខ្លាំងដែលកំណត់ឃើញត្រូវតែអនុវត្តបន្ត និងពង្រីកបន្ថែម ។ ប៉ុន្តែគួរតែផ្តោតការយកចិត្តទុកដាក់លើចំណុចខ្សោយ និងឧបសគ្គក្នុងផ្ទៃដែលមាន ហើយលើកឡើងជាវត្ថុបំណង ។ ឧទាហរណ៍ ប្រសិនបើការវិភាគបង្ហាញថា សាលារៀនមានចំណុចខ្សោយ ដោយសារតែមានសិស្សជាច្រើនមិនបានរៀនរហូតដល់ចប់ថ្នាក់ទី៦ បានទេនោះ វត្ថុបំណងមួយសម្រាប់ឆ្នាំបន្ទាប់នោះគួរតែជាការធ្វើឱ្យប្រសើរឡើងនូវអត្រាឡើងថ្នាក់របស់សិស្ស ។

ខាងក្រោមនេះជាឧទាហរណ៍មួយនៃការវិភាគតាម SWOT ក្នុងការកំណត់ទីតាំងសាលារៀន ដើម្បីធ្វើឲ្យសម្រេចនូវទិសដៅទី១ គឺការប្រមូលកុមារក្នុងវ័យសិក្សាក្នុងជែនទីសិក្សាឲ្យបានគ្រប់ៗគ្នា។ រាល់ក្នុងនានាដែលមានផលប៉ះពាល់ផ្ទាល់ដល់ការប្រមូលកុមារឲ្យចូលរៀនមាន

- គ្រូបង្រៀន
- សាលារៀន
- និងសហគមន៍ ។

ដូចនេះ ការវិភាគត្រូវផ្តោតលើវិស័យទាំង៨នេះ ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងឧបសគ្គ។

តារាងវិភាគតាម SWOT លើកត្តាគ្រូ សាលារៀន និងសហគមន៍

ទិសស្ថ	ចំណុចខ្លាំង	ចំណុចខ្សោយ	ឱកាស	ឧបសគ្គ
គ្រូបង្រៀន	- គ្រូមានធនធានជួយសិស្ស - គ្រូខិតខំធ្វើការ	- ការបង្រៀនមិនមានភាពសប្បាយ - កិច្ចការដែលដាក់ឲ្យកុមារមិនបានលើកកម្ពស់ការខិតខំប្រឹងប្រែងរបស់ កុមារ - ក្ងានការតាំងស្ថាដៃសិស្ស	- ប្រធានកម្រងឈ្មោះ និងមានធនធានក្នុងការជួយនាយកសាលា និង គ្រូ - ការ.អប់រំស្រុកមានគ្រូឧទ្ទេសល្អៗមួយចំនួន - វត្តអាចផ្តល់នូវការជួយឧបត្ថម្ភមួយចំនួន	- ខ្វះគ្រូបង្រៀន - គ្រូបង្រៀនតែងតែផ្ទាល់ចេញនៅក្រោយពេលធ្វើការបាន២ឆ្នាំ - ខ្វះសម្ភារៈ - ខ្វះសៀវភៅសិក្សាពេល
សាលារៀន	- ផ្ទះទៅកាន់សាលារៀនល្អ - សាលាមានរបងដែលកសាងដោយ សហគមន៍	- ពុំមានពត៌មានមានអ្នកមើលទៅនឹងចំនួនកុមារក្នុងវ័យសិក្សា - មិនមានការតាមដាន - ទំនាក់ទំនងរវាងនាយកសាលានិងគ្រូបង្រៀនមិនល្អ	- វត្ត មានទំនាក់ទំនងល្អជាមួយសាលារៀន	- សាលារៀនស្ថិតនៅក្នុងតំបន់ក្រីក្រជាច់ស្រយាល - ខ្វះបន្ទប់រៀន ទោះបីគ្រូប្រើបន្ទប់មួយសម្រាប់២ថ្នាក់ក្តី
សហគមន៍	- ប្រធានសហគមន៍មានទំនាក់ទំនងល្អជាមួយសាលារៀន - ប្រជាពលរដ្ឋមានការយល់ដឹងសិទ្ធស្មារ និងចិត្តបាន - ចៅអធិការវត្តស្ងួត និងមានធនធានជួយការងារអប់រំ	- សហគមន៍មិនមានការចូលរួមនៅ ដែលកើតមានក្នុងសាលារៀន - ប្រធានសហគមន៍មិនមានសមត្ថភាពក្នុងការភ្ជាប់ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍	- ការគាំទ្ររបស់ សហគមន៍មានបងប្អូនធ្វើការក្នុងជួរកងរដ្ឋាភិបាល	- ភាពអសន្តិសុខ - សហគមន៍ក្រីក្រ

ផ្អែកលើពត៌មានខាងលើ សាលារៀននេះមានចំណុចខ្សោយសំខាន់ៗដូចខាងក្រោម ÷

- មិនមានពត៌មានពីចំនួនកុមារក្នុងវ័យសិក្សា
- សាលារៀនមិនមានភាពទាក់ទាញ
- សហគមន៍មិនបានទទួលពត៌មានពីសាលារៀន
- ប្រធានសហគមន៍មិនមានសមត្ថភាពភ្ជាប់ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ ។

ប៉ុន្តែសាលារៀនក៏មានឱកាសដែលល្អបំផុត គឺការទ្រទ្រង់ពីសហគមន៍ និងព្រះសង្ឆ ។ ជាមួយនេះ ផ្អែកលើចំណុចខ្សោយ និងឱកាសខាងលើ យ៉ាងតិចណាស់ត្រូវចាត់វិធានការ២ ខាងលើអាចជា ÷

- ប្រមូលកុមារក្នុងវ័យសិក្សាទាំងអស់ឱ្យចូលរៀន
- ធ្វើឱ្យមានភ្លេងសមរម្យ ការសិក្សាមានសន្តិសុខ និងមានកន្លែងលេង និងផ្តល់កន្លែងសម្ងួតឱ្យបានគ្រប់គ្រាន់សម្រាប់សិស្ស
- កសាងនូវទំនាក់ទំនងល្អរវាងសាលារៀន និងសហគមន៍
- ធ្វើអតិបរមាណកម្មនៃការប្រើប្រាស់ធនធានក្នុងមូលដ្ឋាន ។

(នៅមានត)

លោក អ៊ីង សារ៉ាត់
អតីតអនុប្រធានមន្ទីរ អ.យ.ក.
ខេត្តតាកែវ (ចូលនិវត្តន៍)

ក្ងួនភ្លេចដែលមាតាបិតាជាគ្រូ
ហើយទៅជាអ្នកមានគ្មានគ្រាប់ប្រសើរ
ម្ចិតដែលមានកូនភ្លេចណាបានទៅជា
បណ្ដិតគ្មានដោយគ្រាន់ចម្រុះចេញពីតាមាតាទេ

ស្រីមិនតាមគេសរសេរ

ដំបងក្រញូង និងស្ដេចត្រសក់ផ្អែម

ក្នុង គ.ស.៩៧២ ព្រះអង្គម្ចាស់ចក្រពង្ស ជារាជបុត្រព្រះបាទស័ម្ពុព្រះ បានឡើងគ្រងរាជ្យ ហើយទ្រង់មានព្រះនាមជាព្រះបាទសម្ដេចព្រះចក្រពត្រាធិរាជបរមពិត្រ គង់នៅមហានគរ ។ ព្រះអង្គបានបញ្ជាឱ្យគេកាប់ឈើដើម្បីសង់ព្រះមេរុសម្រាប់បូជាព្រះសពព្រះបិតារបស់ព្រះអង្គ ។ ក្សត្រថ្មីអង្គនេះមានរាជបុត្រាពីរព្រះអង្គព្រះនាមបទុមកុមារ និងសិរីកុមារ ។ ក្រោយមក អ្នកម្នាងកែវមានគភ៌ តែពុំទាន់ប្រសូតនៅឡើយទេ ។

នៅពេលដែលកំពុងកាប់ឈើ បុរសម្នាក់បានយកដំបងក្រញូងមកធ្វើជាដងកូនកាំបិត នោះស្រាប់តែមានប្រែពណ៌ទៅជាខ្មៅទាំងអស់ តែដោយឃ្លានពេកបុរសនោះក៏សុខចិត្តបរិភោគបាយខ្មៅរហូតដល់ឆ្អែត។ បន្ទាប់ពីឆ្អែតបាយហើយ គេបានដឹងខ្លួនថា គេថ្មើរមានកម្លាំងខ្លាំងណាស់ ជាការពិសោធគេគ្រាន់តែប្រទាញដៃមកឈើមួយបន្តិច ដើមឈើទាំងដើមរលំទាំងដើម ។ ឃើញដូច្នេះ កម្មករទាំងអស់ដែលទៅកាប់ឈើទាំងប៉ុន្មានក៏បានចុះចូលជាមួយនឹងបុរសនោះទាំងអស់ទៅ ។ តមកបុរសនេះបានកាប់ឈើក្រញូងមកធ្វើជាដំបងការពារខ្លួនផ្ទាល់ ជាហេតុនាំឱ្យគេទាំងឡាយគ្រប់គ្នាហៅបុរសនោះថា ជា "ដំបងក្រញូង" រៀងតមក។

ចាប់ពីពេលនោះមក ដំបងក្រញូងមានចិត្តក្រអឺតក្រទមចង់ឡើងសោយរាជ្យ។ ពួកអាមាត្យទាំងឡាយដឹងដំណឹងនេះ ហើយក៏ប្រញាប់ប្រញាល់នាំពត៌មានទៅក្រាបបង្គំទូលស្ដេច ។ ស្ដេចក៏បានបញ្ជាឱ្យកងកម្លាំងទាហានទៅបង្ក្រាបដំបងក្រញូង ប៉ុន្តែទ័ពទាំងអស់នោះពុំអាចយកជ័យជម្នះលើដំបងក្រញូងបានឡើយ មិនតែប៉ុណ្ណោះកងទាហានទាំងឡាយបាននាំគ្នាចុះចូលជាមួយនឹងដំបងក្រញូងគ្មានសល់ឡើយ ។

មហាក្សត្រទ្រង់ពិចារណាឃើញថាទ័ពខាងពេកកំផ្ទាក់ប្រឈម ពុំមានត្រូវពឹងលើអាចទប់ទល់ការវាយប្រហារបាននោះ ព្រះអង្គទ្រង់សុគតក្នុងព្រះជន្ម៤៩ឆ្នាំ បន្ទាប់ពីបានគ្រងរាជ្យបាន២៥ឆ្នាំប៉ុណ្ណោះ ។

ក្នុងខែពិសាខ គ.ស.១០០៤ បន្ទាប់ពីបានទទួលពត៌មានថា ព្រះបាទចក្រពត្រាធិរាជបានសុគតហើយនោះ ដំបងក្រញូងដែលជាកូនរាស្ត្រសាមញ្ញម្នាក់បានលើកកងកម្លាំងចូលក្នុងព្រះបរមរាជវាំង ហើយទទួលការអភិសេកឡើងគ្រងរាជ្យជាក្សត្រទី១៦ ទ្រង់មានព្រះនាមជាកេតុមាអមរទេវរាជ ។ ក្សត្រថ្មីនេះបានចេញបញ្ជាឱ្យគេរុករកតាមចាប់រាជវង្សអតីតក្សត្រមកពិឃាតដោយឱ្យផុតទាំងរស់ ។

នៅពេលនោះ ព្រះរាជបុត្រព្រះអង្គម្ចាស់ចក្រពង្សក៏បានគេចភៀសខ្លួនចេញពីទីក្រុង ។ រាជបុត្រាទីពីរ គឺសិរីកុមារដែលមានព្រះជន្ម៥ឆ្នាំ ត្រូវបានមេដោះនាំគេចទៅនៅជាមួយអ្នកស្រុក ក៏ប៉ុន្តែដោយពុំព្រមស្រាតទទេដូចកូនអ្នកស្រុកនោះ នាំឱ្យពួកទាហានស្គាល់ រួចក៏ត្រូវទាហានចាប់យកទៅផុតទាំងរស់ តែដល់ពេលសៀលមានទាហានមិនស្គាល់ឈ្មោះម្នាក់បានឆក់យកចេញទៅក្រវាត់ចោលនៅក្នុងព្រៃទៅ ។ តមកមានព្រះសង្ឃមួយអង្គបានជួបប្រទះរាជកុមារនេះ ហើយក៏រើសយកទៅចិញ្ចឹម ។ ដោយដៃ និងជើងនៅខ្ចីនខ្ចូងមិនអាចដើរបាន ហើយបានត្រឹមតែអង្គុលនោះ

ទើបគេគ្រប់គ្នាហៅកុមារនេះថា ព្រហ្មកិល អ្នកខ្លះទៀតហៅថា ពញាក្រែក ។

បន្ទាប់ពីបានគ្រងរាជ្យសម្បត្តិបាន ៧ឆ្នាំ ៧ខែ ៧ថ្ងៃ ហើយ ស្ដេចក៏ហៅហោរាមកទស្សន៍ទាយ រឿងហេតុការណ៍ដោយពោលថា "ខ្ញុំមានបុណ្យអស្ចារ្យណាស់ តើចាប់ពីពេលនេះតទៅមានអ្នកណាមានបុណ្យលើសនេះអាចដណ្ដើមយករាជ្យពីខ្ញុំបានដែរឬទេ?" ហោរាពិនិត្យមើលក្បួនហើយទាយថា "ព្រះអង្គមានបុណ្យអស្ចារ្យណាស់មែន តែព្រះអង្គគ្រងរាជ្យនៅមហានគរនេះបានត្រឹមតែ៧ឆ្នាំ ៧ខែ និង៧ថ្ងៃតែប៉ុណ្ណោះ តទៅទៀតនៅ៧ថ្ងៃទៀតទេនឹងមានអ្នកមានបុណ្យថ្មីម្នាក់ចូលមកយករាជ្យសម្បត្តិបានហើយ" ។ ពេលឮដូច្នេះស្ដេចស្វាយក្រញូងគិតថា "បើបុរសមានបុណ្យមកដល់មែន អាត្មាអញនឹងសំលាប់បុរសនោះឱ្យខ្ទេចដោយដំបងរបស់អញ បើអញមិនអាចផ្ដាច់បុរសនោះបានទេ អញនឹងព្រមចុះចាញ់ប្រគល់រាជ្យឱ្យទៅបុរសនោះ រួចហើយអញនឹងចាកចេញពីប្រទេសនេះ ដើម្បីកុំឱ្យមានគ្រោះថ្នាក់ដល់អាត្មាអញឡើយ" ។

ពេលដែលប្រជារាស្ត្របានឮទំនាយនេះហើយ គេទាំងឡាយក៏ជឿតាមដោយគ្មានសង្ស័យអ្វីទេ ។ លុះដល់ថ្ងៃទី៧ ប្រជារាស្ត្រទាំងប៉ុន្មានទាំងអស់នាំគ្នាកុះករទៅរង់ចាំមើលអ្នកមានបុណ្យថ្មី ។ ពេលនោះពញាក្រែកក៏អង្គុលទៅជាមួយនឹងគេដើម្បីចង់ឃើញអ្នកមានបុណ្យដែរ ដោយហេតុខ្វាំងពោក ពញាក្រែក ក៏លោតចុះមកតាមក្រោយគេរត់ត្រឡប់មួយ ។ ពេលនោះមានព្រាហ្មណ៍ចាស់ម្នាក់បាននាំយកសេះមួយព្រមទាំងកញ្ចប់បាយ និងទឹកបំពង់មួយទាំងសំពាយមួយដើរឆ្ពោះទៅរកព្រហ្មកិល ហើយសួរថា "ចៅ! តើចៅឯងទៅណា?" ព្រហ្មកិលក៏តបថា "ខ្ញុំទៅមើលអ្នកមានបុណ្យដូចគេឯងទៀតដែរ ប៉ុន្តែខ្ញុំមិនអាចដើរបាន ពីព្រោះខ្ញុំពិការ" ព្រាហ្មណ៍នោះក៏ឆ្លើយវិញថា "ចៅឯងកុំទៅឡើយ ចៅពុំអាចឃើញអ្នកមានបុណ្យនោះទេ ចូរនៅទីនេះហើយ តាសុំផ្ញើសេះ និងសំពាយនេះឱ្យចៅមើលថែរក្សាឱ្យផង ហើយបើចៅឯងឃ្លានចូរបរិភោគបាយកញ្ចប់ និងផឹកទឹកបំពង់នេះចុះ ចាំតាទៅមើលអ្នកមានបុណ្យ កាលណាតាបានឃើញហើយ តានឹងត្រឡប់មកប្រាប់ឱ្យចៅឯងដឹងវិញ" ។ ព្រហ្មកិល តបថា "ខ្ញុំពិការ ខ្ញុំខ្លាចសេះនេះវារត់ចេញទៅ" តាព្រាហ្មណ៍ប្រាប់វិញថា "មិនអីទេ តានឹងមកវិញឆាប់ៗទេ" ថារួច ហើយគាត់ក៏យកបង្ហៀរសេះទៅផ្ដល់និងដៃព្រហ្មកិលភ្លាម រួចយកសំពាយ កញ្ចប់បាយ និងទឹកបំពង់ទៅដាក់ជិតក្បែរព្រហ្មកិលទៀត ហើយក៏ដើរចេញបាត់ទៅ ។ បន្តិចមក សេះក៏ក្រោកឡើងទាញបង្ហៀរឡើងតឹងធ្វើឱ្យដៃរបស់ព្រហ្មកិល ត្រឡប់ត្រង់ឡើង ឃើញដូច្នេះព្រហ្មកិលក៏យកបង្ហៀរសេះទៅផ្ដល់និងដៃម្ខាងទៀត ដៃនោះក៏ត្រូវសេះទាញឱ្យត្រង់ដូចមុនដែរ រួចទៅព្រហ្មកិលយកបង្ហៀរនេះទៅផ្ដល់ និងជើងម្ខាងម្ដងៗ ជើងទាំងអស់នោះក៏ត្រឡប់ជាប្រក្រតីឡើងវិញទាំងអស់ ។ លុះដៃជើងបានជាអស់ហើយ ព្រហ្មកិល ក៏ប្រញាប់ក្រោកឈរឡើងរួចយកទឹកបំពង់លាងសំអាតខ្លួនប្រាណ ធ្វើឱ្យរូបរាងកាយទាំងមូលឡើងភ្លឺថ្លាបាត់ស្នាមស្លាកអស់រលីង ទើបគិតថា "អស្ចារ្យណាស់ហ្ន៎! ដៃជើង និងកាយអាត្មាអញបានប្រសើរបែបនេះ" ភ្លាមនោះព្រហ្មកិលក៏ស្រាយកញ្ចប់បាយបរិភោគ លុះឆ្អែតហើយស្រស់ស្រាយ ខ្លួនរបស់គេមានកម្លាំងខ្លាំងក្លាបរិបូរណ៍រឹងប៉ឹងលែង ទើបឃើញព្រះរាជាថ្លែងអំណរគុណចំពោះតាព្រាហ្មណ៍ទៅក៏លាសំពាយ ឃើញសុទ្ធតែពស្ត្រាភរណ៍ស្រដៀងគ្នាអ្នកជារាជ្យ ព្រហ្មកិលក៏ចាប់លើកយកប្រដាប់ទាំងនោះមកស្លៀកពាក់តែងកាយឡើងភ្លឺបំព្រងល្អដូចទេវតា ទើបគិតថា អាត្មាអញនេះឬដែលជាអ្នកមានបុណ្យនោះ? គិតហើយក៏ឡើងជិះសេះភ្លាម សេះហោះនាំព្រហ្មកិលចេញពីទីសស្ថានត្រង់ទៅព្រះបរមរាជវាំងសំដៅឆ្ពោះទៅរករាជបល្ល័ង្ក ។ ស្ដេចដំបងក្រញូង កាលបើមើលឃើញអ្នកមានបុណ្យគង់លើសេះហោះដូច្នេះក៏ខឹងគ្រោធខ្លាំងណាស់ ហើយ

ឆក់ចាប់យកដំបងយ៉ាងរហ័សត្រវែងទៅរកព្រហ្មកិល តែពុំត្រូវព្រហ្មកិលទេ ដំបងនោះកាត់ប្រហ្ម៖ហ្ម៖ទិសដៅទៅធ្លាក់កប់ក្នុងដីនៅទីមួយបង្កើតបានជាអូរធ្លើង ទីពីនោះហើយដែលគេហៅថា អូរដំបងនោះ។ តាមហេតុនេះក្សត្រដែលគ្រងរាជ្យតមកក៏ហៅជាកន្លែងនេះថា ជា "ខេត្តបាត់ដំបង" រៀងរហូតមកដល់បច្ចុប្បន្ននេះ។

លុះឃើញប្រជាកាន្ត្រ និងកងទ័ពបានចុះចូលនិងអ្នកមានបុណ្យធ្ងន់ហើយ ស្តេចដំបងក្រញូងក៏ព្រមថ្វាយបង្គំសារភាពចុះចាញ់ ហើយថ្វាយរាជបល្ល័ង្គទៅព្រហ្មកិល។ ក្ងាត់បានចាកចេញពីមហានគរ ទៅរស់នៅជីវជ្ជងព្រៃងក្នុងឆ្នាំវកទៅកាន់ប្រទេសលាវ។ ព្រហ្មកិលឡើងគ្រងរាជ្យក្នុងឆ្នាំ១០០៨ ក្នុងព្រះជន្ម១២ព្រះវស្សានៅក្នុងមហានគរ មានព្រះនាមជាព្រះបាទសម្តេច សន្ធ្ងាអនុរាជ។

ជាស្រង់ : លោកស្រី ម្ចិន សារ៉ន

របៀបប្រើពាក្យខ្លះ

១.ពាក្យយោងខ្ពស់ : (ំ) ខ្ញុំ (ុ) គេ(ទាបជាង)

ពាក្យខាងក្រោមណាដែលមានខ្យល់ ុ និងតឹ គេខាងលើមត្រូវសរសេរជួសៈ ុ និង ុ ជានិច្ច។

ឧ. ស្លឹ ស្ងប ដ្ឋៅ ក្ងស ទ្ងាំ ជ្ងេរ ក្ងាត់ ។ល។

លើកលែងតែពាក្យមួយចំនួនមានដូចជា ពុំ(ពាក្យ) ពុំ(ការ) ពុំ(ស) (ឈ្នោះ) ។

២.ពាក្យសរសេរនឹង ឦ :

ពាក្យណាដែលមានខ្យល់ ឦ ត្រូវសរសេរនឹង ឦ ទាំងអស់ លុះតែជា ឧ ឧ ខ្ញ ខ្ញ ខ្ញ ខ្ញ ។ លើកលែងតែពាក្យមួយចំនួនមានដូចជា: ក្ងាយ ក្ងាត ក្ងេងគ្ងាង ។

៣.ពាក្យសរសេរនឹង ឫ និង ឬ :

ឫ និង ឬ ទាំងពីរនេះ ត្រូវស្តាប់ស្រៀងគ្នា តែវាមានកន្លែងប្រើផ្សេងគ្នា។ ឫ ជានេះ គឺប្រើចំណាំថា ឫ មានតែពាក្យ ៨ ម៉ាត់ទេ គឺ: ឫកលោន សឫកូម ឫសម្ងៅ ឫសម្ងៃ ឫស្ងួន ឫកាត ឫក្រាចក្ងុង ឫកាត ឫកាត ។ ដូចនេះ ឬ ទាំងអស់ ជាពាក្យ ថ្មីមកសណ្ដែក ឬកថ្ងៃ ឬកក្រាកង ជាដើម ។

លោក ជ្ងេម ដារ
មន្ត្រីជាន់ខ្ពស់ក្រសួងធ.ទ.ស.
រដ្ឋមន្ត្រីក្រសួង ធ.ទ.ស.

ចិញ្ចឹមកូនអប់រំ

ការដកពិសោធន៍របស់កុមារអាយុ ១២ខែ ដល់ ១៥ខែ

១. នៅក្នុងអាយុ១២ខែដល់១៥ខែ តាមការលូតលាស់រាងកាយនិងបញ្ញា តើកុមារអាចធ្វើអ្វីជាមួយនឹងអ្វីបានខ្លះ?

នៅក្នុងអាយុនេះវាមួយថ្ងៃម្តងមួយថ្ងៃ កុមារមានការលូតលាស់រាងកាយ និងបញ្ញាកាន់តែល្អប្រសើរ យើងសង្កេតឃើញ៖

ក. ចំពោះការលូតលាស់រាងកាយ : រាងកាយកុមារមានការរីកចម្រើនលូតលាស់ទាំងទំហំ, ទម្ងន់, កម្ពស់ និងទាំងសមត្ថភាពចលករ។ តើសមត្ថភាពចលករមានន័យដូចម្តេច? សមត្ថភាពចលករ មានន័យថា ភាពដែលអាចជំរុញឱ្យមានចលនា។ នៅវ័យនេះ កុមារមានភាពម្ចាស់ការក្នុងការធ្វើចលនាផ្សេងៗ។ ដូចនេះ កុមារអាចធ្វើចលនា វារ លូន តោង ឈរ ដើរតេះតះ ឡើង។

ឧទាហរណ៍ : កុមារឡើងកាំជណ្តើរ ឬចុះពីលើគ្រែដែលមានកម្ពស់សមល្មម។ ជាមួយនេះ កុមារអាចធ្វើចលនាជាមួយវត្ថុផ្សេងៗដូចជា ចាប់, កាន់, ទាញ, គោះ, បោះ។

ឧទាហរណ៍ : កុមារទាញដណ្តើមយកប្រអប់ម្សៅពីម្តាយ។ ប៉ុន្តែគ្រប់ចលនាដែលធ្វើរបស់កុមារពុំទាន់រឹងមាំពុំទាន់មានភាពប៉ិនប្រសប់ និងរហ័សរហួននៅឡើយ។ ប៉ុន្តែជាមួយពេលវេលាដែលកុមារកាន់តែចម្រើនឡើង សមត្ថភាពធ្វើចលនាក៏កាន់តែប៉ិនប្រសប់ រឹងមាំ និងរហ័សរហួន។

ខ. ចំពោះការលូតលាស់បញ្ញា : នៅវ័យនេះគំនិតរបស់កុមារកាន់តែទូលំទូលាយ និងសម្បូរបែបឡើងដោយសារគេបានធ្វើពិសោធន៍ច្រើនជងដោយខ្លួនឯងតាមរយៈការលេងល្បែងផ្សេងៗ ការធ្វើពិសោធន៍ផ្ទាល់ដៃ។ ការគិតរបស់កុមារខុសគ្នាពីការគិតរបស់មនុស្សចាស់ ព្រោះកុមារពុំទាន់មានការគិតសមហេតុផលឱ្យបានពេញលេញនៅឡើយ។ កុមារនៅមានការភ័ន្តច្រឡំដោយសារភ្នែក។ កុមារគិត កុមារសួរខ្លួនឯង ការគិតរបស់កុមារមានការផ្សារភ្ជាប់ផ្ទាល់ទៅនឹងបទពិសោធន៍របស់គេ និងចំណេះដឹងដែលកុមារបានទទួលពីមនុស្សដែលនៅជុំវិញ។ ដូចនេះតាមការលូតលាស់បញ្ញាកុមារអាចកត់សំគាល់ ចងចាំចំណុចគោល (ទីតាំង) គេធ្វើការបកស្រាយ គេប្រមូលគំនិតមានលក្ខណៈសកម្មភាពលេងល្បែង សកម្មភាពអប់រំរៀនសូត្រ និងសកម្មភាពផ្សេងៗទៀតដែលមាននៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់គេ។

ឧទាហរណ៍ : មុនពេលលេងល្បែងផ្គុំរូប កុមារពិនិត្យដើម្បីចំណាំរូបភាពនៃបំណែករូបនីមួយៗ និងទីតាំងដែលត្រូវ

ដាក់បំណែកក្រដាសនោះ។ តែនៅពេលលេង សេចក្តីនៃលេងពុំបានត្រឹមត្រូវ គឺកុមារដាក់បំណែករូបខុសទីតាំង។

កុមារនៅពុំទាន់អាចធ្វើចំណាត់ថ្នាក់នៃព័ត៌មាន ពុំទាន់ចេះរិះគិត ពុំទាន់ចេះស្វែងយល់ពីអ្វីដែលមាននៅជុំវិញខ្លួនបាន គ្រប់គ្រាន់ និងល្អប្រសើរនៅឡើយ។ ប៉ុន្តែគ្រប់ព័ត៌មានដែលកុមារប្រមូលបាន កុមារអាចរៀបចំ និងធ្វើចំណាត់ថ្នាក់ព័ត៌មាន ទាំងអស់នោះជាក្រុមៗនៅក្នុងខួរក្បាលដ៏តូចរបស់គេ ហើយជួនកាលគេអាចយកព័ត៌មានទាំងនោះមកប្រើប្រាស់ជាថ្មីបាន ភ្លាមៗក្នុងករណីចាំបាច់។ ឧទាហរណ៍ ៖ កុមារចាំបានថា ការលេងល្បែងផ្គុំរូបត្រូវអនុវត្តតាមលំដាប់លំដោយនៃរាង ទំហំ ឬពណ៌ ប៉ុន្តែពេលលេងកុមារនៅតែមានការភ័ន្តច្រឡំ ពីព្រោះផ្គុំរូបពុំបានត្រឹមត្រូវ។

២. តើមាតាបិតា ឬអាណាព្យាបាលគួរផ្តល់ឱកាសដល់កុមារឱ្យបានហ្វឹកហាត់ធ្វើការ ឬលេងអ្វីដែលគេចង់ដែរ ឬទេ? ព្រោះអ្វី?

ហ្វឹកហាត់ គឺមានន័យថា នាំ ឬទម្លាប់ឱ្យកុមារធ្វើអ្វីមួយដដែលៗច្រើនដង ដើម្បីឱ្យគេមានភាពប៉ិនប្រសប់។

មាតាបិតា ឬអាណាព្យាបាលត្រូវតែផ្តល់ឱកាសដល់កុមារឱ្យបានហ្វឹកហាត់ធ្វើការងារស្រាលៗ ឬលេងល្បែងដែល គេចង់ ព្រោះថាតាមរយៈការហ្វឹកហាត់ធ្វើការស្រាលៗ ឬលេងល្បែងសមស្របតាមវ័យ ធ្វើឱ្យគេទទួលបាននូវភាពប៉ិនប្រសប់ ព្រមទាំងបទពិសោធន៍ និងចំណេះដឹងថ្មី។

ឧទាហរណ៍ ៖ ការជួយបោសផ្ទះម្តងម្កាលឱ្យម្តាយ ការរើសសម្លៀកបំពាក់ច្រើនដងធ្វើឱ្យកុមារមានភាពប៉ិនប្រសប់ (ការ បែងចែក ... ចំពោះទៅ)។

ការផ្តល់ឱកាសឱ្យកុមារបានធ្វើការងារ និងការលេងល្បែងដែលគេចង់បណ្តុះបាននូវភាពជាម្ចាស់ និងភាពពេញចិត្ត ព្រមទាំងក្តីរីករាយយ៉ាងខ្លាំង ជាមួយនោះកុមារបានបទពិសោធន៍ច្រើន និងតាមរយៈការពិសោធន៍ទាំងនោះធ្វើឱ្យកុមារទទួល បាននូវចំណេះដឹងថ្មី កុមារនឹងបាននូវសុខភាពល្អ (កុមារដែលអាចមាន ព្យាយាម រឹងប៉ឹង ពូកែ ជាកូនដែលមិនចេះត្រូវអាច ក្លាហាន មានកម្លាំង) អាចចូលរួមបានគ្រប់សកម្មភាព ពិសេសគេនឹងទទួលបានជោគជ័យក្នុងការសិក្សា និងក្នុងការបំពេញ កិច្ចការផ្សេងៗនាពេលអនាគត។

បើមាតាបិតា ឬអាណាព្យាបាលមិនបណ្តោយឱ្យកុមារបានហ្វឹកហាត់ធ្វើការ ឬលេងទេនោះ កុមារនឹងគ្មាន ការអភិវឌ្ឍន៍ឡើយ ឬបើមានក៏ការអភិវឌ្ឍន៍នោះមានល្បឿនយឺត។

ឧទាហរណ៍ ៖ ឪពុកម្តាយបណ្តោយឱ្យកុមារឡើងជណ្តើរ ដំបូងគេមានការលំបាកមិនទាន់មានភាពប៉ិនប្រសប់ តែ បើកុមារបានធ្វើញឹកញាប់ នោះគេនឹងមានភាពប៉ិនប្រសប់ គឺឡើងជណ្តើរលឿនជាងមុន។

៣. តើការផ្តល់ឱកាសដល់កុមារឱ្យបានដកបទពិសោធដោយខ្លួនឯងនេះគួរស្ថិតនៅក្រោមការត្រួតពិនិត្យ ឬចាំ ជួយពីមនុស្សធំដែរឬទេ? ព្រោះអ្វី?

ការផ្តល់ឱកាសដល់កុមារឱ្យគេបានដកបទពិសោធដោយខ្លួនឯង ចាំបាច់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ ឬចាំជួយពី មនុស្សធំ ព្រោះថាកុមារនៅក្នុងវ័យនេះពុំទាន់មានការអភិវឌ្ឍពេញលេញគ្រប់ផ្នែកនៅឡើយ ពិសេសរាងកាយ និងការ ធ្វើចលនារបស់គេនៅពុំទាន់រឹងប៉ឹង ឬរឹងមាំនៅឡើយ ដូចជាក្នុងការដើរ ការរត់ ការឡើង ... ការ គប់ ឬចោលរបស់ផ្សេងៗ ដែលគេចង់ធ្វើ ... កុមារនៅមានការ យល់ច្រឡំ និងការគិតខុស ដូចនេះរាល់ការធ្វើសកម្មភាពរបស់កុមារ គឺជាការដកបទពិសោធដែលតម្រូវឱ្យមនុស្សធំ ឬ

ចាស់ត្រូវឃ្លាំមើល ឬចាំជួយកុមារជានិច្ច។ ការចាំជួយពីមនុស្សធំ គឺជាការលើកទឹកចិត្ត ការជម្រុញ ការផ្ដល់នូវជំនឿមុតចិត្ត ដល់កុមារ ពោលគឺជួយកុមារឱ្យមានសេចក្ដីក្លាហាន និងមិនខ្លាចក្នុងការសាកល្បងការងារថ្មីៗ ឬសកម្មភាពផ្សេងៗ ដើម្បីសម្ដែងបង្ហាញអំពីសមត្ថភាពដែលគេមានដល់មនុស្សធំ។ មានន័យថា កុមារចង់ឱ្យមនុស្សចាស់ដឹងថា គេក៏អាចធ្វើអ្វីបានដូចមនុស្សធំដែរ។

ឧទាហរណ៍: កុមារមិនចូលចិត្តឱ្យម្ដាយបញ្ចុកបាយទេ គឺគេចង់តាន់ស្លាបព្រាដួសបាយញ៉ាំដោយខ្លួនឯង។

៤. តើសកម្មភាពបែបណាខ្លះដែលយើងមិនគួរឱ្យកុមារធ្វើ ឬលេង?

សកម្មភាពដែលយើងមិនគួរឱ្យកុមារធ្វើ ឬលេង គឺសកម្មភាពទាំងឡាយណាដែលប៉ះពាល់ដល់រាងកាយ និងបញ្ញារបស់កុមារ ពោលគឺសកម្មភាពដែលពុំសមស្របតាមវ័យ និងការលូតលាស់របស់កុមារដូចជាការឱ្យកុមារលេង ឬហ៊ឹកហាត់កុមារឱ្យធ្វើកិច្ចការធ្ងន់ធ្ងរហួសកម្លាំងដូចជាឱ្យកុមារលើក ឬលេងរបស់ដែលមានទម្ងន់ធ្ងន់ពេក ឬដើរឆ្ងាយពេក។ ចំពោះល្បែងលេងវិញមិនត្រូវឱ្យកុមារលេងល្បែងណាដែលមានលក្ខណៈពិបាកស្មុគស្មាញ ដូចជាល្បែងផ្គុំរូបដែលមានច្រើនបំណែកល្បែងផ្សេងទៀតដែលមានឧបករណ៍សម្រាប់លេងច្រើនជាដើម។ ចំពោះកុមារវ័យនេះ អាចលេងល្បែងផ្គុំរូបណាដែលមានតែ ២ ឬ ៣ បំណែក ឯរូបភាពទៀតសោតត្រូវមានលក្ខណៈងាយដែលកុមារមើលឆាប់យល់។

៥. តើគួរមានការលើកទឹកចិត្ត ឬការស្ដីបន្ទោសដែរឬទេ ចំពោះសកម្មភាពទាំងឡាយដែលកុមារបានធ្វើ? ព្រោះអ្វី?

សំណួរនេះពិតជាមានសារៈសំខាន់ណាស់ចំពោះមាតាបិតា ឬអ្នកអាណាព្យាបាល និងអ្នកធ្វើការងារពាក់ព័ន្ធនឹងកុមារ។ ការលើកទឹកចិត្ត គឺជាផ្នែកមួយនៃកត្តាជំរុញទឹកចិត្តដ៏សំខាន់មិនអាចខ្វះបាន ពិសេសគឺជាការផ្ដល់នូវភាពកក់ក្ដៅ ជំនឿមុតចិត្ត និងសេចក្ដីក្លាហាន ព្រមទាំងធ្វើឱ្យកុមារពេញចិត្ត និងរីករាយក្នុងការធ្វើសកម្មភាពគ្រប់យ៉ាង ដើម្បីអភិវឌ្ឍន៍លើគ្រប់ផ្នែក ផ្ទុយទៅវិញការស្ដីបន្ទោស ការបន្តុះបង្អាប់ គឺជាថ្នាំពុល ជាឧបសគ្គរាំងនូវការធ្វើសកម្មភាព ក៏ដូចជាការអភិវឌ្ឍន៍លើគ្រប់ផ្នែករបស់កុមារ។

តាមការសិក្សាស្រាវជ្រាវ ពិសេសតាមរយៈបទពិសោធន៍ការងាររបស់អ្នកធ្វើការងារអប់រំ កុមារតូចជាច្រើនគន្លងមកបានបង្ហាញឱ្យឃើញថា គ្រប់សកម្មភាពដែលមនុស្សធំមានបំណងឱ្យកុមារធ្វើ បើមានការលើកទឹកចិត្តតាមរយៈការបំផុស ការសរសើរ ការផ្ដល់រង្វាន់ដូចជាទះដៃ អង្អែលក្បាល ថើប ឱប ឱ្យវត្ថុអ្វីមួយ... ធ្វើឱ្យកុមារខិតខំបញ្ចេញអស់សមត្ថភាព ដើម្បីធ្វើឱ្យបានសម្រេចនូវលំហាត់ ឬកិច្ចការមួយ។ ផ្ទុយទៅវិញ បើមានការស្ដីបន្ទោស នោះកុមារបាក់ទឹកចិត្តយ៉ាងខ្លាំង ហើយគេនឹងក្លាយទៅជាក្មេងដែលអសកម្មក្នុងគ្រប់សកម្មភាព។

*** ការផ្ដល់ដំបូន្មានសម្រាប់អាណាព្យាបាល**

- ត្រូវផ្ដល់ការលើកទឹកចិត្តដល់កុមារគ្រប់ពេលដែលគេធ្វើសកម្មភាព ទោះបីជាលទ្ធផលពុំសមស្របក៏ដោយ។
- គប្បីចងចាំថា នៅពេលកុមារបានធ្វើការ ឬលេងតាមបំណងប្រាថ្នារបស់គេ ធ្វើឱ្យកុមារនឹងអាចមាន បទពិសោធល្អ ទទួលបានចំណេះដឹងថ្មី មានសុភាពលក្ខណៈក្នុងការសិក្សាខ្លួនឯង និងបំពេញការងារផ្សេងៗ នាថ្ងៃអនាគត។
- ផ្ដល់ឱ្យកុមារបានធ្វើការ ឬលេងល្បែងអ្វីដែលគេចង់ មិនត្រូវបង្ខំកុមារឱ្យលេងតាមចិត្តអ្នក ឬទីកន្លែងណាមួយ ដោយមិនឱ្យកុមារបានធ្វើ ឬលេងអ្វីសោះ ព្រោះតែខ្លាចគេខូច ឬទទួលគ្រោះថ្នាក់ផ្សេងៗ។ ម្យ៉ាងទៀត មិនត្រូវឱ្យកុមារធ្វើការ ឬលេងតាមបំណងរបស់ឪពុកម្ដាយឡើយ។ នាយកដ្ឋានអប់រំកុមារ ត្រូវជ្រើស

គំរូទ្រឹស្តីនៃការអភិវឌ្ឍជំនាញ

សញ្ញាណនៃការអភិវឌ្ឍជំនាញមានន័យថា មនុស្សយើងបានស្ថិតជាប់ជានិច្ចនៅក្នុងលំនាំ ឬដំណើរនៃការអភិវឌ្ឍជំនាញ កាលណាពួកគេធ្វើការងារនៅក្នុងវិស័យណាមួយដែលបានកំណត់ឱ្យ។ បុគ្គលគ្រប់រូបអាចខុសប្លែកពីគ្នាទៅតាមល្បឿននៃការអភិវឌ្ឍ និងទៅតាមចំនោរនៃការអភិវឌ្ឍ។ វាជាកម្រិតមួយដែលសិស្សមានចេតនាចូលរួមធ្វើការងារជាយមានគ្រូជាអ្នកជួយពួកគេ។ នេះគឺជាការផ្សារភ្ជាប់គ្នារវាងការសិក្សាដោយផ្ទាល់ ភាពសកម្មនៃការចូលរួម ការធ្វើការងារជាគ្នា និងជាផលរង្វាន់។

គំរូទ្រឹស្តីនៃការអភិវឌ្ឍជំនាញមានធាតុសំខាន់ ៥ គឺ : ជំនាញពុទ្ធិយល់ដឹងលើសមត្ថភាពផ្ទាល់ខ្លួន ជំនាញសិក្សារៀនសូត្រ ជំនាញគំនិត ពុទ្ធិ និងការជំរុញចិត្តចង់។

ធាតុទាំងអស់នេះជះឥទ្ធិពលលើគ្នាទៅវិញទៅមកដោយផ្ទាល់ និងដោយប្រយោល។ ឧទាហរណ៍ : ការសិក្សារៀនសូត្រនាំទៅរកពុទ្ធិ រីឯពុទ្ធិវិញបង្កការងាយស្រួលដល់ការសិក្សារៀនសូត្របន្ថែមទៀត។

១.ជំនាញពុទ្ធិយល់ដឹងលើសមត្ថភាពផ្ទាល់ខ្លួន : យោងលើការយល់ដឹងរបស់សិស្ស និងការចេះត្រួតពិនិត្យលើការសិក្សារៀនសូត្រផ្ទាល់ខ្លួនរបស់ពួកគេ។ ជំនាញនេះរួមមានឧទ្រឹ្ធ១ដែលសិស្សម្នាក់យល់ដឹងអំពីរបៀបសរសេរអត្ថបទលិខិតស្លាម ឬចេះដោះស្រាយចំណោទពុនអក្សរ។ ទាំងពីរនេះចាត់ទុកជាដំណាក់ដែលជាប់ទាក់ទងគ្នា ហើយតែដំណាក់ទាំងនោះអាចនឹងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពតាមមធ្យោបាយ ឬតាមរបៀបណា។

២.ជំនាញសិក្សារៀនសូត្រ : ជំនាញនេះជួនកាលត្រូវបានបែងចែកជាការសិក្សារៀនសូត្រជាក់លាក់ច្បាស់លាស់ដែលកើតឡើងនៅពេលយើងខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ហើយនិងការសិក្សារៀនសូត្រមិនជាក់លាក់ច្បាស់លាស់ដែលកើតឡើងនៅពេលដែលយើងទទួលយកពត៌មានយ៉ាងងាយ១ ដោយគ្មានការខិតខំប្រឹងប្រែងឡើយ។ មានឧទាហរណ៍ជាច្រើនបានលើកឡើងអំពីជំនាញសិក្សារៀនសូត្រ ដែលបង្ហាញឱ្យឃើញនូវភាពខុសប្លែកគ្នារវាងពត៌មានដែលមានភាពជាប់ទាក់ទងគ្នា និងពត៌មានដែលមិនមានភាពជាប់ទាក់ទងគ្នា រវាងការរៀបចំដាក់បញ្ចូលជាមួយគ្នានូវពត៌មានដែលមានភាពជាប់ទាក់ទងគ្នា នឹងការផ្សារភ្ជាប់ពត៌មានថ្មីៗទៅនឹងពត៌មានដែលបានរក្សាទុកក្នុងលំនឹកចងចាមកហើយ (តាមទស្សនៈរបស់លោក Sternberg)។

៣.ជំនាញគិត : ជំនាញគំនិតមាន ២ ប្រភេទសំខាន់ៗគឺ :

ក-ជំនាញគំនិតទិសៀន ឬគំនិតវិភាគ : រួមមានការវិភាគ ការទិសៀន ការវិនិច្ឆ័យ ការវាយតម្លៃ ការប្រៀបធៀប និងការធ្វើឱ្យឃើញភាពផ្ទុយគ្នា។

ខ-ជំនាញគំនិតច្នៃប្រឌិត : រួមមានការច្នៃប្រឌិត របកគំហើញ ការបង្កើតថ្មី ការបង្កើតរូបភាពអ្នណ៍ ការសន្ធត និងសម្ពាតិកម្ម។

គ-ជំនាញគំនិតអនុវត្តន៍ : រួមមានការអនុវត្ត ការប្រើប្រាស់ និងការហ្វឹកហាត់។ នេះគឺជាដំណាក់ដំបូងនៃការប្រែក្លាយគំនិតទៅជាសកម្មភាពក្នុងពិភពជាក់ស្តែង។

៤.ពុទ្ធិ (ចំណេះដឹង) មានពុទ្ធិពីរប្រភេទដែលជាប់ទាក់ទងទៅនឹងមុខវិជ្ជាសិក្សា ÷

ក-ពុទ្ធិថ្លែងការណ៍ : លើកអំពីហេតុការណ៍ បញ្ញត្តិ គោលការណ៍ ច្បាប់...

ខ-ពុទ្ធិនីតិក្រម : ថ្លែងអំពីនីតិវិធី និងយុទ្ធសាស្ត្រទាំងឡាយ... ។

៥.ការជំរុញចិត្តចង់ : ការជំរុញចិត្តចង់មានច្រើនប្រភេទខុសៗគ្នា ហើយក្នុងទ្រង់ទ្រាយមួយនៃការជំរុញចិត្តចង់នេះ គឺពិតជាចាំបាច់ណាស់សម្រាប់ជោគជ័យរបស់សាលារៀន។ បើគ្មានការជំរុញចិត្តចង់នេះទេ នោះសិស្សច្បាស់ជាមិនខិតខំប្រឹងប្រែងសិក្សារៀនសូត្រឡើយ(តាមទស្សនៈរបស់លោក Mc Clelland, Atkinson, Clark និង Lowell) ។

នវកជន[(១)] -អ្នកសិក្សាគ្រាដំបូង, អ្នកមិនទាន់មានជំនាញ, បុគ្គលិកថ្មី- ធ្វើការងារសំដៅទៅរកភាពជំនាញតាមរយៈការហ្វឹកហាត់ប្រកបដោយមនសិការ និងមានគោលបំណង។ ក៏ប៉ុន្តែការហ្វឹកហាត់នេះទាមទារអន្តរកម្មនៃធាតុសំខាន់ទាំង ៥ នេះជាមួយគ្នានៅក្នុងគំរូថ្មីនៃការអភិវឌ្ឍជំនាញ។ ជាស្នូលនៃធាតុទាំងនេះ គឺការជំរុញចិត្តចង់ដែលជាធាតុសំខាន់នាំមុខគេ។ បើគ្មានធាតុនេះទេ ក៏គ្មានអ្វីៗកើតឡើងដែរ។ ការជំរុញចិត្តចង់ ជំរុញពុទ្ធិយល់ដឹងលើសមត្ថភាពផ្ទាល់ខ្លួនឱ្យដំណើរការហើយ ពុទ្ធិយល់ដឹងលើសមត្ថភាពផ្ទាល់ខ្លួននោះ ក៏បង្កើនសកម្មភាពជំនាញសិក្សារៀនសូត្រ និងជំនាញគំនិតដែលក្រោយមក វាផ្តល់ជាប្រតិកម្មតបទៅពុទ្ធិយល់ដឹងលើសមត្ថភាពផ្ទាល់ខ្លួនវិញដែលជួយឱ្យកម្រិតនៃភាពជំនាញកើនឡើង។ ពុទ្ធិថ្លែងការណ៍ និងពុទ្ធិនីតិក្រមបានមកពីការរីកចម្រើនល្អតាមរយៈនៃជំនាញគំនិត និងជំនាញសិក្សារៀនសូត្រដែលអាច នឹងប្រើប្រាស់បានកាន់តែមានប្រសិទ្ធភាពនៅពេលអនាគត។ ដោយហេតុថាធាតុទាំង ៥ នេះ ជះឥទ្ធិពលលើគ្នាទៅវិញ ទៅមក នោះសិស្សបានឈានដល់ប្រភេទមួយនៃភាពជំនាញ។ ពួកគេបានក្លាយជាអ្នកប្រកបវិជ្ជាជីវៈដែលអាចមានសមត្ថភាពយកផ្នែកជំនាញទាំងនោះទៅប្រើប្រាស់ប្រកបដោយមនសិការ (ក៏ប៉ុន្តែភាពជំនាញកើតមានឡើងនៅច្រើនកម្រិត) ។

<u>មតិយោបល់</u> : ក្នុងថ្នាក់រៀន គ្រូមិនគួរគប្បីបង្ហាត់សិស្សសំដៅទៅរកតែការផ្តល់ចំណេះដឹងមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែត្រូវតម្រង់ទៅរកការអភិវឌ្ឍគំនិតវិភាគ គំនិតច្នៃប្រឌិត និងគំនិតអនុវត្តន៍ដោយផ្សារភ្ជាប់ជាមួយចំណេះដឹងមូលដ្ឋាន។ សិស្សសិក្សារៀនសូត្របានកាន់តែល្អ កាលណាគេគិតគូរ យកចិត្តទុកដាក់អំពីការសិក្សារៀនសូត្រ។

លោក Robert J.Sternberg សាស្ត្រាចារ្យចិត្តវិទ្យានៅសាកលវិទ្យាល័យ យេល (Yale University, U.S.A) បានថ្លែងថា "គឺដល់ពេលវេលាដែលត្រូវដាក់ជំនួសគំរូថ្មីនៃប្រាជ្ញាហើយ" ។

លោក ប៉ែត សុីមហ្ជុ (និក្ខេបជន)

(១) នវកជន (novice) = អ្នកមិនទាន់មានជំនាញ

ជាស្រង់ចេញពី Annual Editions (Educational Psychology 03-04)

[illegible] (ភ)

IV- [illegible]

គណៈកម្មការមធ្យមសិក្សាអប់រំចំណេះទូទៅបានសង្កេតឃើញថា បើសិនភ្នាក់ងារជ្រើសរើសពត៌មានមានប្រភពផ្សេងៗគ្នា គេហដ្ឋាន សាលារៀន អ្នកជិតខាង សហគមន៍ សាសនា អង្គការ និងរដ្ឋ វាពិតជាគ្មានទស្សនៈវិស័យ និងការឯកភាពគ្នាខាងគំនិតនោះទេ ហើយបើវាមានទិសដៅផ្សេងៗ សាលារៀននឹងមានលទ្ធភាពធ្វើឲ្យមានឥទ្ធិពលលើការអប់រំចរិតលក្ខណៈរបស់សិស្ស ។ សិស្សអ្នកនៅតាមតំបន់ជនបទ ជួបការលំបាកក្នុងមធ្យមថ្ងៃ ១ ដើម្បីទទួលយកពត៌មានផ្សេងៗគ្នាជាច្រើន ។

លោក George Tomlison ទស្សនវិទូអង់គ្លេស បានពិយាយថា តម្រូវការនៃសហប្រតិបត្តិការរវាងគេហដ្ឋាន និងសាលារៀនរួមមាន ÷

គេហដ្ឋាន និងសាលារៀនត្រូវរៀបចំតួនាទីរបស់ខ្លួន ដើម្បីត្រៀមលក្ខណៈក្នុងការអប់រំកុមារ ។ ជាពិសេសត្រូវចងចាំថា ការជួបគ្នារវាងឪពុកម្តាយ និងគ្រូបង្រៀនមានសារៈសំខាន់ណាស់ក្នុងការអប្រ៉ំកុមារ ហើយនាំឲ្យយើងសម្រេចបានលទ្ធផលដ៏ល្អប្រសើរនូវអ្វីដែលយើងចង់បាន ។

ជាមួយគ្នានេះ លោក S.Bala Krishna Joshi ចិត្តវិទ្យាឥណ្ឌា បានពិយាយថា កិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធរបស់ឪពុកម្តាយ គឺជាគ្រូបង្រៀនដំបូងគេបង្អស់ជាមួយនឹងគ្រូបង្រៀនទីពីរ ដែលគេចាត់ទុកជាមួយគ្នានៅក្នុងការអប់រំឲ្យបានផ្ទៃផ្ការីកក្នុងដំណាក់កាលបណ្តុះបណ្តាលនៅក្រៅស្ថានសិក្សា ។

ការសង្កេតនេះបានកំណត់ចំណុចជើងថា " គ្រូបង្រៀន និងឪពុកម្តាយ " ដែលបានបោះពាក្យដោយក្រសួងអប់រំឥណ្ឌា ។ វាមានលក្ខណៈសំខាន់ណាស់សម្រាប់ការលូតលាស់ និងមុខងារបស់កុមារដែលគេបានបង្កើតឡើងរវាងសាលារៀន និងឪពុកម្តាយ ពោលគឺជាសមាសធាតុ ២ ក្នុងការបណ្តុះបណ្តាលចរិតលក្ខណៈរបស់សិស្ស ។

ឪពុកម្តាយ និងគ្រូបង្រៀនគួរតែរកឱកាសជួបគ្នា ដើម្បីទទួលយកបញ្ហាផ្សេងៗ និងដោះស្រាយបញ្ហារបស់កូនក្នុងការអប់រំបុគ្គលិកលក្ខណៈឲ្យបានល្អប្រសើរជាងមុន ។ ឪពុកម្តាយ និងគ្រូបង្រៀនត្រូវសហការគ្នាដោយផ្តោតទៅលើការយោគយល់គ្នា ។ ការយោគយល់នេះ ត្រូវលើកលុបចោលក្នុងការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់កូន ។

V- [illegible]

- ផ្តើមចេញពីមតិយោបល់ខ្លះរបស់គ្រូបង្រៀន
- រកឲ្យឃើញនូវតម្លៃមានកម្រិតខ្ពស់របស់ឪពុកម្តាយស្តីពីកូនក្នុងការសិក្សា
- ចេះជួយគ្នាទៅវិញទៅមកដោយគំនិតជ្ជិចផ្តើមពីឪពុកម្តាយក្នុងការចូលរួម
- ចេះជួយគ្នាក្នុងការគ្រប់គ្រងកិច្ចការផ្ទះ
- ជ្រៅនូវភាពចាំបាច់របស់កុមារនៅពេលវៃលាដ៏ជាក់លាក់មួយ
- ចេះជួយអប់រំកុមារឲ្យចេះគោរពច្បាប់សាលារៀន

- ធានាជួយមូលនិធិ និងផ្តល់អំណោយសម្រាប់សាលារៀន
- ផ្តើមចេញពីមតិយោបល់ឪពុកម្តាយក្នុងការណែនាំ
- ត្រូវការផ្តល់ពត៌មានល្អៗដើម្បីជួយអភិវឌ្ឍកុមារ
- លើកគម្រោង និងផែនការផ្សេងៗ ព្រមទាំងប្រែក្លាយវាជាការពិត និងអាចយកជាការបាន
- ចង់បានពត៌មានគ្រប់គ្រាន់ ដើម្បីចំណាយលើការចង់ក្រឹងជ្រៅសារ
- ត្រូវចេះប្រមាណាបញ្ហា មុនពេលក្លាយទៅជាបញ្ហាធ្ងន់ធ្ងរ
- តម្រូវឱ្យសាលារៀនផ្តល់កិច្ចការផ្ទះសម្រាប់កុមារ
- ចង់ដឹងការប្រឹងប្រែងរបស់សាលារៀន ដើម្បីលើកកម្ពស់អភិវឌ្ឍបុគ្គលិកលក្ខណៈរបស់កុមារ ។

VI- ឥណ្ឌានុសត្ថវិធីមន្ទីរសាលាដើម្បីការការពារសុខុមាលភាព ក្នុងសេចក្តីការពារដ៏ល្អនៅសាលារៀន

- ផ្តើមចេញពីមតិយោបល់ខ្លះៗរបស់គ្រូបង្រៀន
- លក្ខណៈមិនពេញចិត្តរបស់សិស្សត្រូវប្រឈមមុខជាមួយធន្ទ:របស់ឪពុកម្តាយ
- ការអភិរក្សន្ទ្រវ៉ាវយោបល់ គឺជាការជោគជ័យលើកម្មវិធីសិក្សា
- កង្វះខាតពេលវេលា ដើម្បីជម្រុញឱ្យសិស្សមានការប្រឹងប្រែងនៅក្នុងទីសណ្ឋានជាកំលាកមួយ
- ការភ័យខ្លាចរបស់សិស្សដែលនឹងអាចឈានទៅរកការអន្តរាគមន៍ពីឪពុកម្តាយ
- ផ្តើមចេញពីមតិយោបល់ខ្លះៗរបស់ឪពុកម្តាយក្នុងការអប់រំ
- ការមិនយកចិត្តទុកដាក់របស់ឪពុកម្តាយចំពោះកិច្ចការសាលារៀន
- ជីវិតដ៏មមាញឹក និងការខ្វះខាតពេលវេលារបស់ឪពុកម្តាយសិស្សក្នុងការទាក់ទងជាមួយគ្រូបង្រៀន ។

VII- ឥណ្ឌានុសត្ថវិធីដើម្បីលើកកម្ពស់ទំនាក់ទំនងជាមួយនឹងឪពុកម្តាយសិស្ស

- គ្រូបង្រៀនគួរតែពិភាក្សាយ៉ាងម៉ត់ចត់ក្នុងការទាក់ទងសកម្មភាពល្អៗជាមួយមាតាបិតាសិស្ស
- គ្រូមិនគួរប្រឈមមុខ ឬបង្ហាញផ្សេងៗជាមួយមាតាបិតាសិស្សនោះទេ
- គ្រូបង្រៀនគួរអនុញ្ញាតឱ្យមាតាបិតាសិស្សចូលរួមជំនួយដោយសន្តិវិធី
- គ្រូបង្រៀនគួរតែសិក្សាអំពីបញ្ហាផ្សេងៗរបស់សិស្សរួមជាមួយសមត្ថភាពរបស់គេ ដើម្បីយកទៅជជែកជាមួយឪពុកម្តាយសិស្ស
- គ្រូបង្រៀនមិនគួរអនុញ្ញាតឱ្យមាតាបិតាសិស្សចោទថា គ្រូបង្រៀនជាអ្នកប្រកាន់ទីម្ចស់សិស្សនោះទេ
- គ្រូបង្រៀនគួរតែណែនាំឪពុកម្តាយសិស្សឱ្យចេះប្រើប្រាស់មធ្យោបាយល្អ ១ និងមានការគ្រប់សមចំពោះកូន
- គ្រូបង្រៀនគួរណែនាំឪពុកម្តាយសិស្សឱ្យទទួលស្គាល់ការពិត ចេះចាប់អារម្មណ៍លើសុខុមាលភាពរបស់កូន
- គ្រូបង្រៀនគួរមានទំនាក់ទំនងល្អជាមួយឪពុកម្តាយសិស្ស ដើម្បីជាដៃគូក្នុងការអប់រំកូនរបស់គេ ។

(នៅមានត)

អនុបណ្ឌិតសួយ សូភាព

ការដើររបស់អ្នកជំងឺបេះដូង

ជំងឺបេះដូងជាជំងឺមួយប្រភេទដែលកើតឡើងហើយធ្វើឱ្យមនុស្សមិនអាចបំពេញការងារបានល្អ ។ ហេតុនេះអ្នកមានជំងឺបេះដូង ឬមនុស្សដែលកើតជំងឺនេះ មានចំនួនកាន់តែច្រើនឡើង ។ ហេតុដូច្នេះហើយពួកគេត្រូវធ្វើសកម្មភាពជាប្រចាំថ្ងៃ ។ គ្រូពេទ្យបានណែនាំអោយអ្នកជំងឺធ្វើលំហាត់ប្រាណ ។ ក្រៅពីថ្នាំព្យាបាល កម្មករ កសិករ អ្នកប្រើកម្លាំងច្រើន មិនសូវមានបញ្ហា តែមនុស្សភាគច្រើនដែលធ្វើដំណើរតាមរថយន្ត ម៉ូតូ ធ្វើការអង្គុយ ស្ទើរតែប្រើកម្លាំងតិចតួច ។ ការទាំងនេះធ្វើឱ្យមានហានិភ័យខ្ពស់ក្នុងការកើតជំងឺបេះដូង ។

ដោយយល់នូវហេតុផលដូចនេះ ទើបគ្រូពេទ្យឯកទេសជាច្រើនដែលបន្ទាប់ពីបានព្យាបាលអ្នកជំងឺបេះដូងហើយ តែងតែផ្ដល់ដំបូន្មានដល់អ្នកជំងឺឱ្យធ្វើលំហាត់ប្រាណដោយការដើរជាប្រចាំរាល់ថ្ងៃ នៅពេលចេញពីធ្វើការ ។ ការធ្វើដំណើរដោយជើងនេះ ត្រូវបង្កើនបន្តិចម្ដងៗ ។ ក្នុងការដើរ អ្នកជំងឺអាចចាប់ផ្ដើមពីការដើរមួយរយៈពេលខ្លីៗ បន្ទាប់មកបង្កើនរយៈពេលដើរឱ្យវែងជាងនេះ តែកើនទៅមុខដែរ ហើយអ្នកជំងឺក៏អាចដើរឱ្យលឿនជាងមុនបន្តិចម្ដងៗផងដែរ ។ ការដើរនេះមួយទៀតដែលប្រសើរបំផុត អាចធ្វើឱ្យអ្នកជំងឺបេះដូងបានធូរស្រាល និងចៀសវាងមរណភាពទាន់ហន់បាន ។

គួរដឹងថា អ្នកមានជំងឺបេះដូង បើធ្វើសកម្មភាពច្រើន ឬខ្លាំង ឬក៏ដើរឆ្ងាយ ឬរត់ភ្លាម អាចមានគ្រោះថ្នាក់ ក៏ប៉ុន្តែគេត្រូវចាប់ផ្ដើមពីតិចទៅមុនទើបបានលទ្ធផលប្រសើរ ។

ដូចនេះ អ្នកជំងឺបេះដូងគួរតែចាប់ផ្ដើមដើរឡើង កុំខ្ជិលច្រអូសអី ។

ដកស្រង់ដោយ ខែម យ៉ាវ



ដេស៊ីបែល

[illegible] បែល (bel) [illegible] ស្គាល់ និងប្រើប្រាស់ខ្នាតមួយ[illegible]នៃរង្វាស់នេះផងដែរ គឺដេស៊ីបែល (décibel) សរសេរកាត់ជា dB ។ ដេស៊ីបែល ប្រើប្រាស់សម្រាប់កំណត់អានុភាពនៃសូរ [illegible] ស្មើនឹង 10^{-12}w ។

បែល គឺយកឈ្មោះលោកក្រាហាមបែល (Graham Bell) ជនជាតិអេកូស ដែលទៅរស់នៅសហរដ្ឋអាមេរិក កាលពីចុងសតវត្សទី១៩ ។ មុខជំនាញរបស់លោក ក្រាហាមបែលគឺគ្រូ និងធ្វើការជាមួយ[illegible] ប្រើវិធីដែល[illegible]ជាមួយ[illegible] ។ លោកបានបើកសាលាមួយនៅឆ្នាំ១៨៧១ ដើម្បីធ្វើការ[illegible] ។ [illegible] និងប្រើប្រាស់[illegible] [illegible] នៅឆ្នាំ១៨៧៦ ។ [illegible] (Elisha Gray) [illegible] បានធ្វើគម្រោងការជាច្រើនទៀត [illegible] ការធ្វើឱ្យ[illegible] [illegible] ។ល។

[illegible]

[illegible] ទៅដល់សាស្ត្រាចារ្យ[illegible] Graham Bell ។

[illegible] ទំព័រ ៣០



Hertz = Hz = ឯកតារង្វាស់ប្រេកង់

(fréquence) => Mégahertz (Mhz)

យកឈ្មោះលោក Heinrich HERTZ

រូបវិទូអាល្លឺម៉ង់ (១៨៥៧-១៨៩៤)

ការប្រើប្រាស់ និងការគ្រប់គ្រងថ្នាក់សិស្ស (៣)

២. តើការងារណា ដែលអ្នកគ្រូត្រូវធ្វើដោយការគ្រប់គ្រងថ្នាក់សិស្ស ក្នុងដំណាក់កាលប្រើប្រាស់?

- .....
.....

- អាចអភិវឌ្ឍប់ណិនការគិតល្អិតល្អន់ប្រកបដោយវិភាគ។ វាអាចជួយសិស្សឱ្យយល់ថា ការសិក្សាមានលើសពីអ្វីដែលគ្រាន់ផ្តល់ការដឹងតែប្រមាណមាត្រ
- អាចជួយសិស្សឱ្យអភិវឌ្ឍប៉ិណិនការគ្រប់គ្រងពេលវេលា និងការរៀបចំផែនការសិក្សា
- អាចជួយសិស្សឱ្យមានការចូលចិត្ត ចង់ចេះចង់ដឹងការសិក្សារបស់ពួកគេ
- អាចជាមធ្យោបាយមួយដ៏ប្រកួតប្រជែងឱ្យសិស្សចូលសិក្សារៀនសូត្រ និងការងារផ្ទះ ជាពិសេសសិស្សដែលមានកម្លាំងល្ងង់
- អាចជួយសិស្សឱ្យមានការគិតលើសពីការសិក្សា ការកត់ចំណាំ ការកត់ត្រាមេរៀន ការប្រៀបធៀបមួយនឹងមួយ ជាដើម។ វាអាចជួយសិស្សឱ្យក្លាយជា ក្លាហានក្នុងការប្តូរមតិ ដោយមានការគោរពនូវមតិផ្សេងទៀត ការដោះស្រាយ: ការដោះស្រាយ ការដាក់ចេញ ការសម្រេចចិត្ត និងការយកការកែតម្រូវ ជាដើម
- អាចជួយសិស្សឱ្យយល់ពីមធ្យោបាយនានាដ៏ល្អសម្រាប់ការសិក្សា។ ឧទាហរណ៍ជាក្នុងមាត្រា ការជួយសិស្សឱ្យយល់ថា ការប្រមូលព័ត៌មានតាមរយៈការសង្កេត ការសម្ភាសន៍ ការសាកល្បង ការប្រៀបធៀប ពន្យល់ និងប្រាប់ប្រធានកិច្ចការនៃពិភពលោក ឬជាដើម ការណែនាំ ពីអត្ថន័យការសិក្សានៃគណិត និងចំនាក់ចំនងច្រើនជាងអំពីចំនួន និងការគណនា
- អាចមានប្រយោជន៍ក្នុងការប្រៀបធៀបផ្ទាល់ជាមួយនឹងការប្រកួតប្រជែងនានាដែលមានជាលក្ខណៈជាកីឬសិលាគមន៍ របស់ពួកគេ

- អាចឯមធ្យោបាយដើម្បីមានសិទ្ធិសេរីភាពនៃការបញ្ចុះបញ្ចូលមាតាបិតាពាក់ព័ន្ធនឹងការសិក្សារបស់កូនៗគេ
- ផ្តល់ឱ្យគ្រូនូវឱកាសមួយឈរសម្លឹងមើលសិស្ស [illegible] មួយដែលធ្វើ[illegible]មួយគ្នា និងឆ្លុះបញ្ចាំងទៅលើរបៀបសិក្សាផ្ទាល់ខ្លួនគេ។ ដោយសារ[illegible] គ្រូ[illegible]ជួយសិស្សឱ្យចេះសិក្សា។ វាជាសំណួរដែលថា គួរតែមានឬមិនគួរតែ[illegible]ជួយសិស្សឱ្យចេះសិក្សារបៀបគិតជាជាងបង្រៀនគេពីរបៀបទន្ទេញ។

៣. [illegible]

ការស្រាវជ្រាវរបស់សិស្ស មិនមែនជាល្បិចដ៏សមរម្យមួយ ដើម្បីប្រើក្នុងស្ថានភាពបង្រៀនទាំងអស់នោះទេ។ ផែនកំណត់ពិសេសមួយចំនួនមានដូចខាងក្រោម៖

- ការស្រាវជ្រាវដោយស៊ីជម្រៅរបស់សិស្ស និងត្រូវការពេលយ៉ាងច្រើន ជាពិសេសក្នុងដំណាក់កាលដំបូង នៅពេលដែលសិស្សកំពុងអភិវឌ្ឍបំណិនស្រាវជ្រាវមូលដ្ឋានរបស់គេ
- ការស្រាវជ្រាវរបស់សិស្ស [illegible] សិស្សគួរទទួលបានឡើយ ពីប្រហែលមកពីសិស្សខ្វះបំណិន ដើម្បីប្រមូល ឬបកស្រាយពត៌មាន ប្រហែលដោយសារកត្តាផ្ទៃក្នុង ដូចជាបរិក្ខារពិសោធដែលមានគុណវិបត្តិ ឬប្រហែលដោយសារដើម្បីពាក់ព័ន្ធការស្រាវជ្រាវ[illegible]
- មិនមែនសិស្សទាំងអស់រីករាយនឹងការសិក្សាប្រភេទនេះទេ។ [illegible]សមត្ថភាពរបស់គេ អាចមាន[illegible]
- សិស្សដែលមានបំណិនអានខ្សោយ [illegible]ទាមទារឱ្យគេប្រើប្រាស់[illegible]
- សិស្សដែលមានបំណិនសរសេរខ្សោយ អាចសិក្សាបានច្រើនពីគម្រោងស្រាវជ្រាវមួយ ប៉ុន្តែអាចមានការលំបាក ដើម្បីបកស្រាយ[illegible]។ [illegible] រឿងពិបាកបំផុតមួយ[illegible]មួយ។ អ្នកអាចធ្វើឱ្យ[illegible]សរសេរ[illegible]
- សិស្ស[illegible] មិន[illegible]មិនមានបំណិនស្រាវជ្រាវល្អ ការសិក្សាតាមការស្រាវជ្រាវ ទាមទារឱ្យមាន[illegible] សិស្ស[illegible]និងមិនមានសមត្ថភាពនេះទេ
- សិស្ស[illegible] [illegible]ទិន្នន័យមុនពេលដែលគេមានភាពច្បាស់លាស់អំពីអ្វីទៅដែលជាបញ្ហាស្រាវជ្រាវដែលគេកំពុង[illegible]ឡើយ។ ការខិតខំរបស់គ្រូ ដើម្បីផ្តោតអារម្មណ៍ទៅលើសិស្ស ហើយឱ្យពួកគេត្រៀមដោយប្រុងប្រយ័ត្ន មុនពេលការ

ចាប់ផ្តើមប្រមូលទិន្នន័យអាចធ្វើឲ្យសិស្សមួយចំនួនរសាយចិត្ត

- ប្រសិនបើសិស្សមិនបានចូលរួមនូវកិច្ចការណាមួយ ត្រូវកត់ត្រាសិស្សនោះពិចារណា លើយមើលឃើញថា លំហាត់ធ្វើឲ្យខាតពេលវេលា។ គ្រូអាចត្រូវចំណាយពេលពិចារណា ដើម្បីជួយសិស្សយល់ពីទិន្នន័យដែលគេបានប្រមូល
- ប្រសិនបើគ្រូមិនបានធ្វើផែនការលើគម្រោងស្រាវជ្រាវរបស់សិស្សណាយ៉ាងប្រុងប្រយ័ត្នខ្លាំងទេ គម្រោងការទាំងនោះ ក្លាយជាមិនអាចចាត់ចែងបានត្រឹមត្រូវ។ ប្រសិនបើរឿងនេះបានកើតឡើង លើយសិស្សមិនអាចបញ្ចប់គម្រោងការបានទេ ពួកគេអាចបាត់ទឹកចិត្តលើការចូលរួមទម្រង់នៃការសិក្សាបែបនេះនាពេលអនាគត។

(នៅមានត)

អនុបណ្ឌិត ម្ចូ សុផារ

ឯកសារ

ការណែនាំសម្រាប់ការវិភាគ ÷

- ការធ្វើឲ្យមានភាពខុសគ្នានៅក្នុងថ្នាក់រៀន : ពេលវេលា ឥណ្ឌានៃសិក្សា សៀវភៅសិក្សា និងភាសា
- សកម្មភាពបង្រៀន : រៀបចំតាមវចនានុក្រម ដាក់ជាសិស្សជាមធ្យមណ្ឌល សម្ភារៈ ប្លុកការសមស្រប
- ការបណ្តុះជ្រាលវិជ្ជា និងគ្រប់ម្រាមសាលារៀន
- ការពង្រីងលំហូរចំណេះដឹង
- ជ្រាលវិជ្ជា និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន
- នយោបាយលើកកម្ពស់គុណភាពអប់រំ : ប្រមូលទិន្នន័យ ដើម្បីកំណត់ពីកត្តាមួយ ឥសាមសមត្ថភាព
- ការមិនមានខុសគ្នា ជានានាភាព ម្ចាស់ការ។

ក្រសួងអប់រំ យុវជន និងកីឬ

ការណែនាំសម្រាប់ទាំងអស់គ្នា ២០០៥

ទ្រឹស្តីសម្ព

[illegible]

- តើកុមារត្រូវចេះធ្វើអ្វីខ្លះ មុនដែលចាប់ផ្តើមរៀនអាន?
- តើមានអ្វីកើតឡើងនៅក្នុងខួរក្បាលរបស់កុមារដែលរៀនអាន?
- តើកុមារដែលជួបការលំបាកក្នុងការរៀនអាចបណ្តាលមកពីមូលហេតុអ្វី? តើយើងត្រូវធ្វើដូចម្តេចចំពោះពួកគេទាំងនោះ?

១.ការកំណត់ពីចំណាត់ថ្នាក់ផ្សេងៗនៃការអភិវឌ្ឍរបស់កុមារ

ភាពចុំដោរនៃខួរក្បាលរបស់កុមារ ប្រព្រឹត្តទៅតាមដំណាក់បន្តបន្ទាប់ផ្សេងៗតាមតួនាទីរបស់វា ÷

- តាំងពីកំណើតរហូតដល់អាយុ ១៥ខែ : ទារកមានការអភិវឌ្ឍ លូតលាស់វិញ្ញាណទាំងឡាយ (លំនឹង ការស្តាប់ កាយវិញ្ញាណ ឃានវិញ្ញាណ ជ្ជិហ្វាវិញ្ញាណ និងចក្ខុវិញ្ញាណ) ។ ចំពោះយន្តការចលនា ទារកបានផ្លាស់ប្តូរពីដំណាក់រង្គិចទៅដំណាក់ម្ចាស់ការលើសាច់ដុំទាំងឡាយ ។
- [illegible] ទៅ ២ឆ្នាំ : [illegible] ។
- ពីអាយុ ២ឆ្នាំ ទៅ ៧ឆ្នាំ : [illegible] ។ ភាពចុំដោរនៃ [illegible] ។ [illegible] ។
- ពីអាយុ ៧ឆ្នាំ ទៅ ៩ឆ្នាំ : ដំណើរការអឡូតោល "សមហេតុផល" ផ្តែកខាងក្រោម។ ការយល់ពីភាព លំអិត និងធាតុផ្សេងៗនៃភាសា ការបកស្រាយផ្តែគណិតវិទ្យា ការអភិវឌ្ឍកាយសម្បទាសម្រាប់រៀនអាន និងរៀនសរសេរ ។
- អាយុ ៨ឆ្នាំ : ខួរក្បាលផ្តែកខាងមុខមានការអភិវឌ្ឍផ្តែកចិត្តចលភាពដែលមានតោលដៅ ការពិនិត្យអាកប្បកិរិយារបស់មនុស្សក្នុងសង្គម ការអភិវឌ្ឍនៃភាសាមានក្នុង (កុមារអាចពិចារណាមុនដែលនិយាយចេញមក) ។
- ពីអាយុ ៩ឆ្នាំ ទៅ ១២ឆ្នាំ : [illegible] ។

ដំណាក់ផ្សេងៗនៃការអភិវឌ្ឍនេះ ដូចគ្នាចំពោះកុមារគ្រប់រូប ប៉ុន្តែល្បឿននៃការកើតលូតលាស់ត្រូវអាស្រ័យទៅតាមចង្វាក់របស់បុគ្គលម្នាក់ៗ។ ដូចនេះ ដើម្បីធានាបានទទួលជោគជ័យនៃការសិក្សារបស់កុមារ គេត្រូវពិចារណាឱ្យបានម៉ត់ចត់ចំពោះដំណាក់ផ្សេងៗនៃការកើតលូតលាស់ និងចង្វាក់នៃការអភិវឌ្ឍជាបុគ្គលនៃកុមារម្នាក់ៗនៅក្នុងការងាររៀន និងបង្រៀន ។

២.ភាពចុំនៃប្រព័ន្ធសរសៃប្រសាទក្នុងការរៀនអាន

អ្វីៗទាំងអស់នេះដើម្បីត្រៀមកុមារក្នុងការរៀនអាន ÷

ផ្នែកសោតវិញ្ញាណ

ស្តាប់បានល្អ ប្រែងចែកសូរស័ព្ទដែលមានលក្ខណៈស្រដៀងគ្នា (ឧទាហរណ៍ : សូរ [ង] និង [ស] ឬ សូរ [កង] ។ និង សូរ [កង់]

ពេលឮសូរសំឡេង មានប្រភពពីទិសណា : ខាងក្រោម ខាងលើ... ជាសំឡេងអ្វី? បានមកពីអ្វី...)

គោរពតាមបញ្ជា ឬឆ្លើយតបទៅនឹងការណែនាំ ឬស្តាប់រឿងនិទាន ហើយចងចាំព័ត៌មានដែលខ្លួនបានឮ ឬរៀបរាប់ពាក្យ ឃ្លា និងការណែនាំផ្សេងៗឡើងវិញ

- វិភាគសំឡេង : ផ្តោតអារម្មណ៍ ស្តាប់សំឡេងណាមួយដោយមិនយកចិត្តទុកដាក់នឹងសំឡេងផ្សេងៗទៀត។ អាចរកសូរណាមួយនៅក្នុងពាក្យ។ មានសមត្ថភាពលេងល្បែងសិក្សាលើការរកពាក្យជួន (ពាក្យដែលបញ្ចប់ដោយអក្សរដូចគ្នា ឬសូរដូចគ្នានៅក្នុងល្បះ ឬអត្ថបទ)
- ចងចាំពាក្យណាមួយក្នុងចំណោមពាក្យទាំងឡាយដែលស្តាប់ឮ (ឧទាហរណ៍...)
- មានសមត្ថភាពនិយាយ ឬបញ្ជា ឬធ្វើតាមការណែនាំ ឬរៀបរាប់ដោយឡើងវិញ។

ផ្នែកការមើលឃើញ

- មើលឃើញបានល្អ
- ចំណាំការមើលឃើញជុំវិញខ្លួន
- អាចរៀបរកភាពលំអិតផ្សេងៗ (រកឃើញភាពដូចគ្នា ឬខុសគ្នា រវាងរូបភាពពីរដែលខុសគ្នាបន្តិចបន្តួច) ដើម្បីឈានទៅរកការកំណត់ឱ្យបានដោយត្រឹមត្រូវ ។ អាចប្រៀបធៀបរូបរាងផ្សេងៗ ឬទំហំ ពណ៌ ទីតាំងនៃវត្ថុផ្សេងៗ (ការស្គាល់ពណ៌ រាងខ្វែង) កាត់ផ្តាច់ពាក្យ ឬឃ្លាចេញពីប្រយោគ
- រៀបចំ ផ្គុំវត្ថុផ្សេងៗដែលមិនរៀបរយ ដាក់តាមកន្លែងដើមវិញ ... ឬរៀបតាមលំដាប់ (រូបភាពរឿង ...)
- មានការចងចាំ (ចងចាំរូបភាព ទិដ្ឋភាពណាមួយ ... ក្រោយពីបានឃើញរួចហើយ)
- មានការចងចាំចង្វាក់ (រៀបរូបភាព តួរជាចង្វាក់ តួរ ឬរៀបតាមលំដាប់)
- មានសមត្ថភាពចម្លងតាមគំរូ

ផ្នែកចិត្តចលភាព

- ម្ចាស់ការក្នុងការចាប់កាន់អ្វីមួយ ឬការប្រើប្រាស់ដៃ

ការធ្វើចលនាម្រាមដៃឱ្យបានច្រើន (កាន់កន្ត្រៃ លាញ់ដី ចាប់ដង្កៀប ចាប់ ចង្កឹះ ... ដែលបានស្តាប់ឮ ឬដែលបានឃើញ...)

ចម្លើយ

ពុនមិនណិត

ក~



ខ~



:ហនុងំនបក្ជុ

ឯ~ ចាញ្ជាកម់ដូដេក្ជុនហាដនិហ្ជាកបូហាដនលត្រិម្ជិងាមន្ធរំបនហ់ាញ្ជាបំចេ

ឯ~



ដកស្រង់ និងប្រែសម្រួល : គែម យ៉ារ

ញ្ជាហ្ជាកបូហាដនលមាដ៉ាយពុនដលំនកញ្ជុបំកូចេ

មើលគេអ្ជកមាន គេមិនអត់យ្ជាន មានកាសប្រាត់ចាយ
ព្រោះគេបានស្តាប់ នូចច្ជាប់ធីពូកម្ជាយ ធើបបានសប្ជាយ
នាលោកនេះហោចម

ចតិប្ជិត ឯ ទុង

សិក្សាសង្គម

ខ្មែរ

ភូមិវិទ្យា

- ថ្នាក់ទី ៥ • មេរៀនទី ៣៥ : អាកាសធាតុប្រទេសកម្ពុជា
- សៀវភៅសិស្សទំព័រ ៤៣-៤៤ បោះពុម្ពឆ្នាំ ២០០០
- សៀវភៅគ្រូទំព័រទី ៨៨ បោះពុម្ពឆ្នាំ២០០១

អត្ថបទជំនួយ:

តើត្រូវធ្វើយ៉ាងណាខ្លះ ដើម្បីជៀសពីគ្រោះថ្នាក់រន្ទះ?







៣ ៤ ៥

ចម្លើយ:

◆ នៅក្នុងផ្ទះ

▪ មានដែកក្រូចរន្ទះ គោងនៅឆ្ងាយពី :

- [illegible] - ខ្សែអគ្គិសនី
- [illegible] - មាត់ទ្វារ និងបង្អួចធំៗ

▪ [illegible]

- [illegible] ខ្សែអង់តែនវិទ្យុ ទូរទស្សន៍

◆ នៅក្រៅផ្ទះ

- [illegible]
- របស់ណាដែលនៅជាប់នឹងដី - ក្នុងជង្រុក ឬជើងខ្ទម
